ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

BUDDHIST INSTITUTE LIBRARY

## កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ៦

ខែ ៧, ៨, ៩, រួមគ្នា

កុង្ស៊ីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

BIBLIOTHEQUE ROYALE DU CAMBODGE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៧៧

គ.ស. ១៩៣៤

អ្នកទទួលខុសត្រូវ: ជុំ-មៅ

## សូមជូនដំណឹងដល់អ្នកមើលទស្សនាវដ្ដីកម្ពុជសុរិយា

---

ក្នុងឆ្នាំទី ៦ នេះ សៀវភៅទស្សនាវដ្ដីទាំង ១២ ខែ រួមមកដេរផ្ចាប់គ្នាជា ៤ ក្បាលវិញ គឺក្នុង ១ ក្បាលមាន ៣ ខែ ៗ ដែលយើងធ្វើដូច្នេះនេះ គឺប្រយោជន៍ដើម្បីឲ្យបានរហ័សឆាប់ផងនឹងឲ្យបានធូរសោហ៊ុយក្នុងការចូលបោះពុម្ពនោះផង ព្រោះសៀវភៅទស្សនាវដ្ដីក្នុងឆ្នាំនេះបន្ថយថ្លៃចុះមកត្រឹម <u>៤ រៀល</u> ក្នុង ១ ឆ្នាំ ហើយចំនួនទំព័រនៅដដែល ថែមមានរឿងរ៉ាវកាន់តែប្លែកពីរោះច្រើនជាងឆ្នាំមុន ៗ ។

យើងមានសេចក្ដីសង្ឃឹមថាអ្នកមើលទស្សនាវដ្ដីទាំងអស់គ្នា នឹងមានសេចក្ដីសង្ឃឹមទុកចិត្តលើយើងតទៅ ហើយនឹងចុះឈ្មោះជាវជាថ្មីឡើងទៀតមិនខាន ។៚—

ព្រះរាជបណ្ណាល័យកម្ពុជា

# បញ្ជីរឿង


ទំព័រ

១– និរាសនគរវត្ត - ពាក្យកាព្យរបស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទរៀបរៀង . . . . . ៥

២– បុណ្យឆ្លងគំរប់ ២០ ឆ្នាំ សាលាបាឡី, ១០ ឆ្នាំ ព្រះរាជបណ្ណាល័យនិង ៥ ឆ្នាំ ពុទ្ធសាសនបណ្ឌិត្យ . . . . . . . . . . . . . . . . . . . . . . ៨២

៣– សត្ថធនសូត្រ - ឧកញ៉ាភក្តីរាជាយ៉ុាង អាចារ្យបង្រៀនសាលាបាឡីជាន់ខ្ពស់ រៀបរៀង . . . . . . . . . . . . . . . . . . . . . . . . ១០៤

៤– សាសនប្រវត្តិ បរិច្ឆេទទី ៦ ព្រះមហាពិទូរក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យរៀបរៀង (ត) . . . . . . . . . . . . . . . . ១១៣

៥– ឯកសហស្សរាត្រី ឬមួយពាន់មួយយប់, ក្រមការជុំ-មៅ ប្រែចេញពីភាសាបារាំងមកជាភាសាខ្មែរ (ត). . . . . . . . . . . . . . . . . . . . ១២៨

៦– រឿងព្រេងខ្មែរមិនទាន់ដែលចេញផ្សាយ:

១– រឿងអណ្តើកនឹងស្វា . . . . . . . . . . . . . . . . . . . ១៥២

២– រឿងឈ្មោះមៅចូលសាសន៍ចាមយកប្រពន្ធ . . . . . . . . . . . ១៥៥

៣– រឿងសំឡាញ់ពីរនាក់នៅត្រូវជាមួយគ្នា . . . . . . . . . . . . ១៦៤

៤– រឿងបុរស ៥ នាក់ ទី ១ ក្បាលទំពែក, ទី ២ សំពោរហៀរ, ទី ៣ ពព្រៀកភ្នែក ទី ៤ សំទក់ជើង . . . . . . . . . . . . . . . ១៧៣

៥– រឿងបុរសកំជិល - មានប្រពន្ធគ្រប់លក្ខណ៍ . . . . . . . . . . . . ១៧៦


# រូបថតពុម្ព


រូបទី ១– ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្សទ្រង់យាងមកបើកពិធីបុណ្យនៅព្រះរាជបណ្ណាល័យ . . . . . . . . . . . . ៨៤

រូបទី ២– លោកសង្ឃ ៣៥ អង្គ ចំរើនពុទ្ធបរិត្តក្នុងបន្ទប់ធំព្រះរាជបណ្ណាល័យ . . . . . . . . . . . . . . . . . . . . . . . . ៩០

រូបទី ៣– កាលព្រះសិទ្ធត្ថចេញទ្រង់ព្រះផ្នួស . . . . . . . . . . . . . ១០០

រូបទី ៤– ប្រាសាទព្រះគោ ក្នុងប្រជុំអង្គរ-ទីទៀនក្រោមដែលរៀបដូសជុលឡើងវិញ . . . . . . . . . . . . . . . . . . . . . . . . ១១២

# TABLE DES MATIÈRES


Pages

1° — Un pèlerinage à Angkor en 1909 — Poème composé par l'Oknha Suttantaprichéa Inn................. 5

2° — Description des fêtes qui eurent lieu à l'occasion des 20e, 10e et 5e anniversaires de la création de l'Ecole Supérieure de Pâli, de la Bibliothèque Royale et de l'Institut Bouddhique..................... 82

3° — Sattadhana Sûtra, traduit du Pâli en cambodgien par feu Oknha Phéakdey Réachéa Yaing, Professeur à l'Ecole Supérieure de Pâli.................... 104

4° — Sāsana Pravatti ou l'Histoire des religions (chap. VI), par Préas Maha Pitou Krasém, pandit à la Bibliothèque Royale (suite)......................... 113

5° — Eka Sahasrarātrī ou les Mille et une nuits, (contes Arabes) traduit du français en cambodgien par Kromokar Choum-Mau (suite)...................... 128

6° — Contes populaires cambodgiens inédits :

I — La tortue et le singe......................... 152

II — Le nommé Mao qui, par amour pour une malaise, devient musulman................. 155

III — Les deux amis qui font ensemble leur études et qui ont le même professeur.............. 164

IV — Les quatre amis, dont l'un chauve, le 2e morveux, le 3e atteint de paupiérite et le 4e d'éléphantiasis.................... 173

V — Le paresseux dont la femme est vertueuse... 176


## ILLUSTRATIONS :


I — Sa Majesté le Roi Sisowath-Monivong vient célébrer les Fêtes Commémoratives........ 81

II — Prières des 35 bonzes dans la grande salle de la Bibliothèque Royale..................... 90

III — Le tableau vivant représentant le grand Départ............................. 100

IV — Prah Kô (Parc d'Angkor) Soubassement reconstitué............................. 112

# កាព្យ

## និរាសនគរវត្ត

ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

រៀបរៀង

៙ និរាសរតន៍វត្តនគរសែនវិចិត្ត កាលចេញចាកលោក បរសមរមិត្រ កែវជីវាគូជីវិតភិសម័យ ។ ដោយមានការបក្រ-ពង្សវង្សក្រស័ត្រ ស៊ីសុវត្ថិព្រះកែវហ្វាសុទ្បាខ្សែ ព្រះចៅក្រុងកម្ពុជាធិបតៃ មានព្រះទ័យហ្មាយប៉ង[illegible]ពោធិញាណ ។ ទ្រង់យាងមកនគរវត្តសមោសរ ចាត់បដិសង្ខរណ៍ទីបុរាណ បរិ-ច្ចាគរាជទ្រព្យប្រដាប់ទាន បំពេញញាណសម្ពោធិបញ្ញា ។ កំណត់ថ្ងៃយាងនោះបុះខាងខ្នើត ប្រាំបួនកើតភទ្របទមាសា ថ្ងៃព្រហស្បត៍លេខ ៥ ឆ្នាំរកា ពេលសុរិយាជ្រេសែង[illegible]រង្សី ។ លោកចៅហ្វាយខេត្តស្រុកព្រះដំបង ជានាយកងចាត់ការរាជការថ្មី ព្រមទាំងលោកកុម្មិស្សែរអធិបតី បិត្តភ័ក្តិត្រេកត្រង់ទាំង

ទ្វេហា ។ រៀបចាត់បែងតែងតួតាមទំនួល ទៅទទួលព្រះបម
បោច័ក្រា លោកក៏យកខ្ញុំបាទទៅផងណា ព្រោះមេត្តាបង់ឲ្យ
យល់ទីបូរាណ ។ គ្រាន់នឹងខ័តទទឹងប្រសាសន៍លោក ក្រែង
ជួនស្មោកកើតទោសមោះដល់ប្រាណ ខំតែកាត់បិត្តលះលា
កល្យាណ គូបូរាណកាលកម្មចាំបាកបរ ។ ដល់ពេលផ្ទឹម
លោកធំបុះបាកស្ពាន ឡើងរថយានទិមសេះដ៏បវរ សារថីជំ-
នាញទាញបើកបរ បទបរបុះដល់កំពង់ទឹក ។ ពួករាជការ
បារាំងទាំងខ្មែរយួន សឹងតែងខ្លួនជូនដំណើរអ៊ឹកធឹក ពួកទា-
ហ៊ានជើងខ្មៅប្រចាំសឹក ដង្ហែគ្រឹកបុះកប៉ាល់ជាស្រេង ។ នាយ
តៃកុងទាញខ្សែស្រះប្លេកង លាន់បីដងម៉័តឡូស្រាវយិថ្កា សះទិម
ពេញក៏បេញបមឧត្តរា តាមគង្គាហូរត្រង់ដំរង់បរ ។ តៃកុង
យួនបេះក្បួនបង្កូតត្រង់ កាត់ដំរង់តាមជ្រោយប្រាំងសាគរ ចក្រ
ក៏វិលវាយទឹកពន្លឹកខ្ទរ អ្នកនគររត់មើលគ្រប់លំនៅ ។ កប៉ាល់
លឿនដល់គយខ្ញុំគយគន់ យល់ដំបន់មេគយប្រចាំផ្លូវ មាន
សសរគោមតាំងមុខលំនៅ មើលៗទៅទីលំនៅមិនសមសក្តិ ។

ផ្ទះយាកតាករយាលស្បូវយោង  ភាពជាខ្មែរតែជារោងយោង ជាថ្នាក់  ឱគយនេះយ៉ាងជាគ្នាខាត់ប្រាក់  គ្រាន់តែត្រួតមើល អ្នកចូលចេញក្រៅ ។ នឹងមានហួតពន់ជាការក៏ទេ  គ្រាន់ តែគេចូលប្រាប់ក៏ហួសទៅ  ឱគយនេះឥតពន់ធន់តាំងនៅ ធ្វើ តែស្រូវជាំប្បារបំការស៊ី ។ រាជការសៀមតាំងគយនៅចុងស្រុក ពុំឃើញមានទំនុកឡេហួតអ្វី  កោតមេគយនៅចាំជាប្រក្រតី រាជការថ្មីលោកលើកពុំបំរុង ។ ឱអ្នកគយគេធ្វើចំការស្រែ មិនជួញប្រែយ៉ាងយើងអ្នកស្រុកក្នុង  កោតគេរកធន់ជានគ្មាន កោងកុង  ស៊ូផុកផុងជិតកាយក៏ឥតឋា ។ ស្ដាយតែរូបនារី រាងស្រឡៅ  ចុះស្ទូងស្រូវត្រូវកំដៅព្រះសូរិយា  ជិតទាំងជីផុក ផង់ហ្ម៉ាងភក្ត្រា  អនិច្ចាជាតិអ្នកក្រត្រដទៅ ។ ប្រសិនមាន មាសប្រាក់នឹងសក្ដិយស  ស៊ីក៏ខ្ពស់ដេកក៏ខ្ពស់ឥតមោះមៅ បំរុងលាបទឹកអប់នឹងប្រេងម្សៅ  កាល់ចាប់ខ្មៅតែងខ្លួនឡេន្ទួន ល្អង ។ តែងប្រក្លួតអ្នួតឆោមប្រលោមប្រុស  ត្រកូលខ្ពស់ យល់ហើយមិនកន្លង  នេះមកត្រូវកំដៅផុកឌង់ផង នឹងស្នាល

ស្ទុងបងចិត្តស្ទិទ្ធម្តេចបាន ។ គន់ៗគិតអាណិតនារីតូច កើតក្នុងពូជហ៊ើនយេស់ខុសសន្តាន តោងត្រដនឿយយ៉ាកលំបាកប្រាណ ទម្រាំបានមាសប្រាក់ធ្លាក់ដល់ចាស់ ។ ចាស់ហើយតើនឹងតែងតួម្តេចល្អ ប្រុសនឹងតថ្លៃទិញយល់ក្រណាស់ ឃើញជាបុះថ្លៃហោកល្មមបោកប្រាស ការសង្វាស់នឹងសង្វាតជាប់សង្វៀង ។ សម្នាងទន់ក្រធន់តោងធន់អត់ ក្តីនឿយហត់រកស៊ីតាមដំណែង គេអ្នកមានគេតែងកាយបំពៀង មិនដូចខ្លួនន្លួនឯងផុកស្រម៉ក ។ អង្គុយគន់នារីឡ្យភិសៈរង់ កប៉ាល់លឿនដល់បុងអន្សូងសក ស្តុងក៏តូចបទក៏ខ្លីបីប្អូនប្រែក សំ-ណាត់កកដេរដាសពាសពេញស្តុង ។ នាយតែកុងកាប់ច័ក្រពុះសំណាត់ ច័ក្រក៏កាត់ខ៍តណែនកប៉ាល់នឹង ពួកម៉ាត់ឡូចាក់ឆ្នោលដោលទទឹង ច័ក្រក៏រឹងផាត់វិលកប៉ាល់វា ។ ពួកអ្នកឆ្នោលរឹងដោលសំណាត់ញែក កប៉ាល់ជ្រែកវែកប្រានបានមួយគ្រា សំណាត់បុកកប៉ាល់ជាប់ច័ក្រខ៍ពា មើលទៅនាច័ក្ររើសំណាត់រត ។ ខ្ញុំគន់មើលសំណាត់រ៉ាត់កប៉ាល់ ដូចរាគ

កាល់រូបកាយចុះជាតិ ពុំឲ្យរូបរើរូបពីទីល្វិត បំបាំងបិទត្រៃ
លក្ខណ៍បាត់រស្មី ។ កាមរាគរោលរិតសត្វក្នុងលោក ឲ្យសត្វ
នៅសៅសោកក្នុងលោកិយ៍ រាំងកប៉ាល់ដូចរូបយើងប្រុសស្រី
ប្រាជ្ញាខ្វីមិនយល់កល់ត្រៃលក្ខណ៍ ។ ស្លាបច័ក្រគឺបញ្ញាផ្ការ
កប្បណ៍កាត់ កងសំណាត់គឺរាគឲ្យលោកធ្លាក់ បានរូបបេញ
បាកទុក្ខសោករោគរាក់ អាស្រ័យច័ក្រគឺបញ្ញាក្លៀវក្លាហាន ។
គ្រឿងកប៉ាល់ដូចកល់អាការយើង ដីទឹកភ្លើងខ្យល់គឺធាតុ ៤
ស្ថាន បង្គួតគឺសតិរំឭកបាន ហ្មៀលដោលប្រានគឺសមាធិ
ចិត្តដាក់ ។ សំណាត់គឺបាបធម៌និវរណៈ បិទបាំងកៈមិនឲ្យ
យល់ត្រៃលក្ខណ៍ ទឹកហូរវិល់ដូចកល់សង្សារច័ក្រ ឲ្យសត្វ
ធ្លាក់នៅក្នុងអន្លង់កាម ។ ឱអនិច្ចារូបកាយមិនណាយលោក
អំពីរាគនៅតែវង់ក្រឡឹងតាម បានជាជល់ទុក្ខមកយំរហាម
ព្រោះមិនតាមពុទ្ធកិច្ចភ្លេចស្មារតី ។ ខ្ញុំគិតៗ គួរសង្វេករូប
អាត្មា មកលុះចុះតណ្ហាការលោកិយ៍ ឃើញធម៌ហើយក៏នៅ
តែនឹកស្រី ជាបំណើរាគរិតបិទមុខមាត់ ។ កាប់មិនបានប្រានមិន

ប៉ែរឹងតែបិទ អាណាចបិត្តអាណិតបៅមកប្រាសព្រាត់ គ្រាន់នឹង
តាមព្រះបន្ទូលជាបន្ទាត់ លោកិយ៍អត់កត់មិននឹងទទឹងគាង។ យក
ធម៌ព្រះមកលះភ្លើងមិនឈប់ ងងិតឈឹងដូចយប់មិនយល់ភាង
ឱលោកិយ៍លះក្រគ្រាន់តែព្រាង ដូចគេលាងព្រៃខ្មៅត្រូវជ័រទឹក។
ខំដុសលាងយ៉ាងណាមិនឡើងពណ៌ ជាតិជាជ័រជាប់នៅខ្មៅ
ស្រមឹក ដូចកិលេសជាប់សត្វបាត់ជាសឹក អ្នកកុំនឹកគិតលាង
ឲ្យជ្រះបាន ។ ដូចរូបខ្ញុំខំលះរិតតែរឹង ទប់មិននឹងតាំងមិននៅ
ផ្សរកម្មដ្ឋាន អង្គុយគិតយកធម៌ទរមានប្រាណ ដូចគេប្រាន
សំណាត់សាត់មួយគ្រា ។ ដល់ហួសទៅសំណាត់សាត់មកវិញ
ប្រមូលពេញដូចដើមឈើខ្លួនណា ឱសំណាត់នេះប្រៀបដូចត្លួ
តណ្ហា នឹងកាប់ឆ្ការយ៉ាងណាក៏ណែនវិញ ។ គន់សំណាត់
សាត់ជាប់បុងបំការ ទាំងខ្មោចក្អែខ្មោចឆ្មាត្រាពាសពេញ ខ្លះ
រលួយខ្លះប្រេះពោះវៀនបេញ ក្អែកត្មាតដេញគ្នាស៊ីជាភក្សា ។
ខ្ញុំគន់មើលសាកសពបំណីក្អែក គិតសង្វេកដល់រូបនៃអាត្មា ឱ
សត្វក្អែកមកលុះក្តីមរណា សូន្យជីវាគេបោលបណ្តែតទឹក ។

កាលពីរស់កឹងកាបអំណាបមាន សត្វតិរច្ឆានជួបគ្នាមិនបាន ចឹក ដល់ខ្លួនស្លាប់គេអូសបណ្តែតទឹក ក្អែកត្មាតត្រឹកចឹកស៊ី មិនគ្រាន់ឡើយ ។ ឱអនិច្ចាសង្ខារសត្វទាំងឡាយ តែបែកកាយ រំលាយខ្លួនទៅហើយ គេក៏កើតខ្ពើមឆ្អើមពុំជិតឡើយ យើង គេអើយគួរគិតផ្លូវអនិច្ចា ។ ខ្ញុំបាទខំសង្វេកសាកអសុភ រាគ មិនឈប់បេះតែពោលទាំងរូបា នឹកតែទៅដល់ពៅកែវសុគា អនិច្ចាថាតែមាត់ចិត្តមិនចំ ។ អសុភ ១០ សម្រាប់លោកលាង លាក កំចាត់រាគបារិតចិត្តបរម ព្រះយោគីលោកសមាធិចុះ អារម្មណ៍ ប្លែកតែខ្ញុំពុំចំអារម្មណ៍ឡើយ ។ យកសពផ្អែមក ប្រែនឹងរូបកាយ មិនរសាយណាយសោះណាលោកអើយ ធ្វើ ម្តេចហ្ន៎បានលោកឯណាអើយ ជាកោះត្រើយណែផ្លូវឲ្យទានរ៉ា ។ មួយសង្ស័យនឹងពាក្យអន្សងសក ពាក្យប្រែបកដូច្នេះគួរសង្កា សត្វអន្សងវាសកពីកាលណា បានជាមកសញ្ញាឈ្មោះយ៉ាង នេះ ។ សត្វអន្សងមិនដែលសកសោះទេ នេះហេតុអ្វីក៏គេហៅ ដូច្នេះ ឬគេឃើញសំណាកនៅនេះឯង បានជារិះរំព្រះនាមមកត

ឡ្សរ ។ រីឯពិនិត្យគិតមិនយល់សែនធ្ងល់ពេក ការឈ្មោះប្លែក
នាមសត្វពាត់មិនត្រូវ អន្សង់សកលោកណាឲ្យនាមហៅ បាន
ជានេះនាមជាប់តឡ្សេះ ។ តែបើគិតគួរកោតលោកបុរាណ
បេះគិតអានសន្មត្តិនាមយ៉ាងនេះ ទីព្រៃហោះបះឲ្យឈ្មោះប្លោះ
ប្លែះ ពេញជាបេះកម្ពត់កត់នាមនៅ ។ អង្គុយគិតបិត្តភ្លើនរំ-
ភើយខ្យល់ កប៉ាល់គ្រឿនលឿនដល់ព្រែកក្របៅ ទឹកក៏នឹង
ពុំហូរបុះទៀតទៅ ឃើញទឹកខ្មៅថ្លាយង់តគរាគា ។ ក៏ដឹងជា
ជាទឹកទន្លេដល់ ទឹកស្ទឹងកល់ក្បែរទល់ប្រសប់គ្នា បានជានឹង
ពុំហូរត្រឹមណោះណា នឹកសង្កាព្រែកក្របៅហៅសែនធ្ងល់ ។
ព្រែកនេះតើបែកមកពីណានោះ ឃើញតែបុងត្រឹមណោះមិន
ឃើញគល់ ឬព្រែកនេះទំនាបជាភាពទាល់ គួរពិភ័លបិត្ត
ណាស់ព្រែកក្នុងព្រៃ ។ ព្រែកនេះតើគេជីកឬកើតឯង លោក
មកតែងនាមក្របៅនៅប្លេះនែ ខ្ញុំពីគ្រោះមិនអស់ក្តីសង្ស័យ
កប៉ាល់លឿនដល់កន្ត្រៃថ្ងៃក៏ទាប ។ ព្រែកកន្ត្រៃកាត់ត្រង់ត្រូវ
កញ្ញះ ទីស្រែឡ្សះគេដើរបានរៀងរាប ព្រៃដុះព្រោះបុះតាមទីទំ

នាប អ្នកស្វែងលាភរកត្រីអាស្រ័យបាន ។ ព្រៃកកញ្ជះទីស្រ-
ឡះគេដើរដល់ ស្រុកមង្គល់បូរីជាជ័យៈឋាន គិត ៗ ទៅគួរកោត
លោកបូរាណ បេះគិតអានបាត់ព្រៃកឈ្មោះប្លែកគ្នា ។ មួយ
សង្ស័យនឹងនាមកន្ត្រែនេះ នរណារិះបាត់ឈ្មោះទុក្ខប្នេះណា
វិស័យទីជាស្ពានព្រៃព្រិក្សា មកស័ញ្ញាហៅកន្ត្រែសង្ស័យស៊ុន ។
ឬកន្ត្រែលោកណាធ្លាក់នៅនេះ បានជារិះយកនាមនេះមកគុណ
ឬមានជាងកន្ត្រែគេនៅមុន ឬអ្នកបុណ្យឲ្យឈ្មោះព្រោះជាប់គ្នា ។
រំពឹងគិតមិនយល់ដល់ព្រលប់ ពេលក៏យប់ម៉ោង ១ ដល់បាក់
ព្រា តែកុងទាញសះប៉្លែឡើងបីសា ប្រាប់នាវាឲ្យបៀសក-
ប៉ាល់ចូល ។ លុះចូលដល់ស្ពានផែមុខសាលា បោះយុថ្កា
បតបងតាមទំនួល លោកមោនសៀនាយគយចិត្តស្រោះស្រួល
មកទទួលលោកធំទៅត្រីហា ។ ចៅភ្ន័កងារនាំឧសផ្ទុក
កប៉ាល់ ដាក់ពេញទាល់ទាំងល្វែងនៃនាវា លោកបាល័ដ្ឋ
បាត់លៀង ១ វេលា ទាំងអស់គ្នាគេសែនសប្បាយចិត្ត ។
តែខ្ញុំ ១ ព្រួយប្រាណរំខានសល់ ចង់តែដល់បានយល់ចមប-

ពិត្រ អស់រាជការនឹងបានវិលស្ថានស្ថិត មិនដឹងគិតកែផ្លូវឲ្យត្រូវឡើយ ។ អង្គុយគិតដើរគិតដូចពុលផ្សិត រាគក៏រិតរោលរាលរាមិនស្បើយ លុះដល់ម៉ោង ២ ខ្យល់រំភើយ គ្រាន់លំ-ហើយក្តីទុក្ខពីមុខបាន ។ មើលទៅស្ទឹងបាក់ព្រាជាផ្លាធំ ពួកអ្នកឈ្នួញមកជុំទាំងបីដាន មួយគឺស្ទឹងមង្គលបូរីស្ថាន ពីរគឺដានព្រះដំបងបីទន្លេ ។ ទីស្ទឹងនេះកាលរាជសៀមបាយបែកបាត់ឲ្យហៅសាមប៉ែកភាសាគេ ព្រោះដានបីចេញទៅមាត់ទន្លេ បើតាមគេឃើញត្រូវជាផ្លូវបី ។ ឯពាក្យហៅបាក់ព្រាពីបូរាណ គ្មានភិយ៉ានឡាក់ឋាននឹងរូបអ្វី ឬបាក់ព្រាបាក់នេះជាពាក្យថ្មី បូរាណស្តីថាបាត់កំបិតព្រា ។ នរណាបាត់កំបិតនៅនេះឯះ បានជាជាប់នាមនេះដូច្នេះណា ស័ព្ទកំបិតយល់លើសយាររាបា មកស័ព្ទថាតែបាក់ព្រាវិញ ។ ឱបានលោកប្រាជ្ញណានឹងស្សូរសាក ឲ្យដឹងពាក្យបាក់ព្រានេះឯងមិញ រំពឹងទៅមិនយល់សល់សែនម្ញេញ កាលណាលោកនឹងចេញកប៉ាល់ទៅ ។ រំខានទុក្ខនឹងមុសវាយាយី ឯណា

ទុក្ខនឹងស៊ីម៉ែមីទៅ ឯណាទុក្ខនឹងនឹកដល់ឆោមឆ្មៅ ឯណាទុក្ខនឹងក្តោបផ្អៀតគ្នា ។ នឹកទន្ទឹងបានតិបលេបឡុងព្រុតលាបសសុទ្ធអ៊ុំឯបមកម្ទីម្នា លោកកុម្មីសែរក៏ឡើងកាន់នាវាវ៉ុងឡ្យស្រាវយុក្តាបេញវើៗ ។ ខ្ញុំគ្រាន់ស្មើយក្តីមោះព្រោះបង់ឆាប់ ប័ក្ររឹងកប្បណ៍ទឹកខ្លាតខ្លួរទាំងព្រៃ កប៉ាល់គ្រឿនលឿនលើផលាល័យ បើកអស់ដៃមើលព្រៃប្រប៉ះគ្នា ។ ដល់ត្រៃភាពកាប់ប្រែបែឧត្តរ ក៏រឹងបរតាមបទទីគង្គា នឹកសង្ស័យបៃត្រៃភពនេះមហិមា តាំងនាមាឃើញកើនលើសប្រមាណ ។ ពាក្យត្រៃភពប្រារព្ធនាមព្រះពុទ្ធ មិនគួរគេមកបុតឈ្មោះភូមិស្ថានទីនេះសោតពួក នសាទគេរាប់អាន តាំងជាស្ថានបាយ៉ាបបាប់ត្រីទេ ។ នេះហេតុអ៊ីយកនាមព្រះឲ្យឈ្មោះ មិនគួរសោះនឹងពាក្យអ្នកទន្លេ នរណាឯះបាត់នាមនេះមុនគេ ឬគេគ្មេរព្រោះព្រែកបែកបីភ្លោះ ។ សព្វត្រៃភពប្រែឋាភព្វទាំងបី ព្រះជិនស្រីជាត្រៃភពបំពោះ ព្រោះព្រះអង្គវិសេសគុណាពីរោះ បានជាឈ្មោះព្រះបមត្រៃភព្វភារ ។ ឯព្រែកនេះពុំឃើញវិសេសអ្វី

វិសេសតែនឹងត្រីជាអាហារ ពុំគួរតាំងនាមស្មើសាស្តាចារ្យ ឬហៅដោយវោហារអស្ចារ្យក្រៃ ។ រំពឹងគិតមិនយល់សត្វត្រៃភព្វ បង់តែឈប់ទៅមើលទីនោះនៃ ជាមានអ្វីសាក្សីកណ្តាលព្រៃ គួរសង្ស័យនឹងពាក្យត្រៃភព្វនេះ ។ ឬសត្វត្រៃហៅក្រៃលោកតាំងឈ្មោះ គង់ពីគ្រោះតាមហេតុមានប្ហោះប្ហុះ ឬពីដើមព្រះយាងមកនៅនេះ បានជារិះតាំងហៅត្រៃភព្វហោង ។ ឱលោកណាដឹងការហេតុដើមដាន សូមមេត្តាប្រោសប្រាណប្រាប់ខ្ញុំផង ខ្ញុំពីគ្រោះមិនយល់រឹងមូហ្មង ក-ប៉ាល់ឆ្លងកាត់យោគយាងយាវខ្វី ។ លឿនលន្លិមតាមបទយាងយាវត្រង់ កាត់ដម្រង់បែត្រង់ដល់ភូម៏ប្ញី ភូម៏នោះមានគេនៅជាប្រក្រតី បទក៏ខ្លីជាប់នាមពាមសីមា ។ ឱស្រុកពាមបាត់នាមឈ្មោះពីរោះ គេប័ញ្ចុះសីមាពីកាលណា ត្រើយខាងជើងមានព្រែកបែកជាស្នា ឮគេហាស្ទឹងនោះទៅទឹកជោរ ។ ឱទឹកជោរទឹកហូរពីភ្នំណា ធ្លាក់មកពាមសីមាជាសពេញពោរ ទឹកទន្លេឡើងកល់ទល់មិនហូរ កាត់ទឹកជោរដល់ព្រាត់វត្តឈើ

ខ្មៅ ។ គន់មើលទៅវត្តលោកលើគោកស្រួល ជាទីទួល
សមជាអារាមនៅ ឯវត្តនេះយកនាមឈើមកហៅ នាមឈើ
ខ្មៅលោកណាតាំងនាមនេះ ។ ឬវត្តនេះស្រីខ្មៅចៅធ្វើទេ
យកនាមគេមកតាំងទុកដូច្នេះ ឬពីដើមមានឈើខ្មៅនៅនេះ
បានជាវិះតាំងនាមមកឥឡូវ ។ ពាក្យឈើខ្មៅហៅហាក់នាម
ខ្មៅបង ចិត្តចាប់បងនឹកដល់កែវឆោមឆ្លៅ ឱព្រះគុណព្រះកែវ
វត្តឈើខ្មៅ ខ្ញុំលាទៅនគរវត្តព្រាត់កន្និដ្ឋា ។ សូមព្រះគុណ
ប្រោសជួយចក្រពង្ស ឲ្យស្ដេចទ្រង់បំរើនដោយយស្មា ប្រោស
ប្រាណខ្ញុំឲ្យបានទីឧកញ៉ា កបសក្ដារុឡ្លីសុសុវត្ថិ ។ មែន
បើខ្ញុំសម្រេចដូចប្រាថ្នា ខ្ញុំនឹងគិតហៃផ្កាមកថ្វាយថ្វាត់ សូម
កុសលព្រះគុណជួយបំបាត់ សព្វទុក្ខរោគខាត់សកលកាយ ។
មួយសូមជ័យជំនះឈ្នះសត្រូវ ទៅតាមផ្លូវកុំឲ្យមានអន្តរាយ
ទាំងពាលម្រឹគយង់ឃ្នងផងទាំងឡាយ បៀសឲ្យឆ្ងាយដោយ
អំណាចព្រះបមត្រៃ ។ ខ្ញុំសំពះបន់ព្រះវត្តឈើខ្មៅ កប៉ាល់
គ្រឿនលឿនទៅតាមជលាស័យ ត្រូវព្រះពាយរំភើយខ្ញុំគឿយ

ក្រៃ ក៏លក់តាមសម័យយប់នោះឯង ។ លុះបើកដល់មាត់ពីរបេញទន្លេ កប៉ាល់រេបើកពុះឆ្លងវាលវែង វាបុះយោគផាត់មករលកផ្សេង ខ្ញុំបាទឯងក៏ក្រោកចាកដំណេក ។ អង្គុយគន់មើលទឹកទន្លេសាប ឡើងលិចដាបព្រៃព្រឹក្សព្រឹក្សពេក មើលទៅទិសទក្សិណសែនវិវេក ឃើញតែមេឃមូលជិតងងឹតឈឹង ។ គន់ទៅទិសឧត្តរតតិសាណា ឃើញដាដានព្រៃវង់វែងរឹង មើលទៅទិសបស្ចិមវាលដូចបឹង ទឹកឡើងនឹងពោរពេញមើលល្បោះៗ ។ កប៉ាល់រឹងព័ក្រដើរស្មើមិនឈប់ រលកខ្ទប់ស្មើខ្ទាត់ព័ក្រពាតពុះ រលកយោលខ្ចោលឡើងដូចគេបោះ កបាល់ស្ទុះទឹកបែកព្រែកសាចជះ ។ វាយុបោកកប៉ាល់បែលលេឿនរលកគ្រៀនព័ក្រគ្រាន់បើកជំនះ តែកុងកាប់តាមកៀនរលកជះ កប៉ាល់រះទឹកវាយបែកហ្កាត្រែង ។ មើលទៅទឹកធំពន្លឹកគួរតែខ្លាច រលោមស្វាចលិចព្រៃមើលបែកផ្សេង នឹកសង្ស័យទន្លេសាបនេះឯង លោកណាតែងនាមត្រូវទំនងម្លេះ ។ ពាក្យហៅថាទន្លេគ្មេមិនដល់ សព្វនេះយល់មិនត្រូវពាក្យអ្នក

បេះ បាឡីទឹកគ្មានត្ថ (ទ) ទេឯះ ហៅជលេជ្ជប្នេះទើបបានត្រូវ ។ នេះមកហៅទន្លេអក្សរ (ទ) ជាយក (ជ) ជា (ទ) ឬម្តេចក្ខូវ ត្ថ (ន) ជាវគ្គន្តប្រែកបនៅ ស្តាប់ ៗ ទៅមិនត្រូវពាក្យបាឡី ។ ឬបូរាណគេហៅជលេទេ ដល់ក្រោយយារពាក្យគេកើតពាក្យថ្មី ទៅជាហៅទន្លេខុសបាឡី ឬសំដីបូរាណហៅយ៉ាងនេះ ។ ឬ សព្ទនេះជាពាក្យសង្ស្ក្រឹត លោកប្រសិទ្ធ៏ត្ថ (ជ) ជា (ទ) ឯះ ធ្វើម្តេបហ្ន៊ុំបានអ្នកប្រាជ្ញណាបេះ នឹងសាកសួរសព្ទនេះឲ្យប្បាស់ រ៉ា ។ ឱទន្លេនេះធំមើលបាត់ត្រើយ លោកណាអើយមកសាង យ៉ាងប្នេះណា ឬក៏កើតពីបរិមកល្បា ជាធម្មតាទឹកដីពីបូ-រ៉ាណ ។ នឹក ៗ ទៅគួរកោតធម្មតាម្លេះ បេះរិះឲ្យកើតជាភូមិ ស្ថាន ជាទន្លេព្រែកស្ទឹងបឹងបួបាន សម្រាប់ទុកជាស្ថានមច្ឆា នៅ ។ ទីខាងលើបេះធ្វើជាទួលគោក សំម្រាប់លោកអាស្រ័យ នៅឥតសៅ តាំងជាភ្នំក្រមប្តូតទៀតទៅ ជាលំនៅសព្វសត្វ ម្រឹគបក្សី ។ ឱធម្មតាបេះបាត់ជាជាន ៗ សម្រាប់ទុកជាស្ថាន យើងលោកិយ៍ លោកណាឯះបង្កើតអស់ទឹកដី តាមបាឡីហា

កើតដោយធម្មតា ។ តែខាងសាសន៍អារាប់នូវផ្សាបាម គេស្តី
តាមដំរាភិហារថា ទឹកដីនេះគឺអង្គព្រះអាឡ្ល យៈហោវ៉ាគេ
សាងសម្រាប់លោក ។ ខ្ញុំពិគ្រោះមើលតាមគម្ពីរថា ឃើញ
ខុសគ្នានឹងហេតុទឹកដីគោក បើអាឡ្លសាងមែនគួរអធ្យោក ឲ្យ
ត្រូវគ្នាទាំងលោកនោះយល់មែន ។ នេះទឹកដីនឹងសព្វសត្វ
មនុស្សម្នា ឃើញពីរុធខុសគ្នាទៅទាំងផែន ឯណាល្អក៏ល្អ
លើសទាំងដែន ឯណាសោសោសែនទាំងភារា ។ ដូចដីយើង
បាត់ដំបងជាតិដីខ្មៅ ធ្វើស្រែស្រូវកើតផលតែរាល់គ្នា ស្រុក
សៀមរាបម្តេចដីខ្សាច់មុហិមា ធ្វើបំការស្រែស្រូវមិនសូវផល ។
មួយគឺខាងយូរុបម្តេចបាត់ល្អ មនុស្សក៏សប្រិនធំទាំងសាកល
ខាងឥណ្ឌៀមនុស្សខ្មៅៗពិកល ខាងមណ្ឌលយើងម្តេចមនុស្ស
តូបទាប ។ មួយព្រឹក្សាលតានាមដូចគ្នា រសឱជាម្តេចខុសគ្នា
រៀងរាប ទាំងសត្វសោតក៏ខុសអត្តភាព ខ្លះក៏ទាបខ្លះក៏ខ្ពស់
ឃើញខុសគ្នា ។ បើអាឡ្លសាងមែងម្តេចដូច្នោះ ខ្ញុំពីគ្រោះ
មិនសមនឹងថ្វាថា វិស័យព្រះនោះប្រៀបដូចបិតា គោងមេត្តា

ដល់បុត្រស្មើព្រះទ័យ ។ នេះមកសាងឲ្យកូនមិនស្មើមុខ ជា
អាពុកមនុស្សឬខុសនិស្ស័យ ស្លាប់ទៅយល់មិនត្រូវអធ្យាស្រ័យ
ទឹកដីព្រែកកើតដោយធម្មតា ។ ដូចយ៉ាងទឹកទន្លេនឹងសមុទ្រ
ឃើញធំផុតទូលាយឆ្ងាយណាស្វា ពួកអ្នកឈ្មួញដើរជួញរក
ភោគ្គា សឹងសែនមហាលំបាកដោយព្យុះខ្យល់ ។ ឬអាឡាតប្ដូ
ពួកអ្នកឈ្មួញ មិនឲ្យគ្នាដើរជួញក្រោមណ្ដាល់ បានជាមក
បង្កើតជាព្យុះខ្យល់ ឲ្យលិចលង់ទូកទល់ទាល់វិទនា ។ អើបើ
យ៉ាងខ្មែរយើងមិនបូលុសាសន៍ គួរធ្វើផ្លាស់ទៅបុះក៏ផតជា បុះ
ពួកផ្កាដែលគ្នាខំឧស្សាហ៍ ប្រដិបត្តិសព្វគ្រាតាមមហាម៉ាត់ ។
ឯណាយប់គ្នាបួសកាន់ខន្តី ថ្ងៃឡើងឆ្លៀតបង់ត្រីសំលេះសត្វ
ឯណាគ្នាហ៊ានឲ្យតុកតួនកាត់ ខំប្រដិបត្តិមហាម៉ាត់មិនឲ្យឆ្គង ។
គួរឬអាល័សៈឡើមិនប្រោសប្រាណ មកក្លែងធ្វើផលបានធំ
កន្លង គ្នានាំព្រៃទៅលក់ស្រុកបាត់ដំបង ឲ្យគ្នាហ្មងឆ្លងទៅ
ត្រូវព្យុះខ្យល់ ។ បើយើងជាអាល័សៈឡើមិនធ្វើប្អេះ ទីត្រង់
ណោះគួរធ្វើឲ្យកើតប្អល់ ឲ្យអ្នកទូកៈដើរស្រួលមិនតោងល្វល់

នឹងព្យុះខ្យល់ដូចយ៉ាងអាឡាសាង ។ ទីត្រង់ណុះគួរសាងជា
កោះធំ ឲ្យភិរម្យមនុស្សនៅទាំងសងខាង តាំងក្បាលកោះឲ្យ
កើតជាព្រះប្រាង្គណ៍ មានមាត់បាងចូលចេញឲ្យសប្បាយ ។
នេះអាឡាមកសាងទន្លេសាប ដាលតែទឹកទៅរាបទូលាយ
ឆ្ងាយ មនុស្សទៅមកសែនយ៉ាកលំបាកកាយ ព្រោះអន្តរាយ
ដោយខ្យល់តែរាល់គ្នា ។ អើពួកជ្វាគេថាព្រះគេសាង នឹង
ឯបអាងមិនសមនឹងកិរិយា ពាក្យនេះអញ្ជើញពិចារណា ជា
យកខាងធម្មតាឬអស់លោក ។ ឬយកខាងព្រះអាឡាដែល
ថានោះ សូមពិគ្រោះមើលចុះតាមអធ្យោក ឯទឹកដីថ្ងៃខែស-
ម្រាប់លោក គួរប្រយោគមើលហេតុមើលកិរិយា ។ កប៉ាល់
ដើរលុះដល់ចុងភ្ញៀសហ្វាត់ តែកុងបាត់ចូលបតបោះយុថ្កា នាំ
គ្នាដេកសម្រានតាមធម្មតា អនិច្ចាតែខំពុំលក់ឡើយ ។ ពុល
រលកភ្នករលឹកនឹកដល់ផ្ទះ កត់មិនឈ្នះគះមិននឹងព្រលឹងអើយ
ត្រូវមកដេកកប៉ាល់ខ្យល់ល្ហើយៗ ផាត់រំភើយរលកបោកផាៗ ។
គន់ទៅខាងឃើញសើនគោមពីរភ្លោះ ភ្លើងភ្លឺប្រោះប្លុងៗក្នុង

គង្គា គោមពីរនោះឆេះនៅសព្វវេលា តាំងជាផ្លាប្រាប់ទ្វារស្រុក សៀមរាប ។ ខាងមាត់ពីរក៏តាំងគោមឆ្វេងស្តាំ អុបប្រចាំ ចូលចេញទន្លេសាប ខ្ញុំគន់ៗនឹកកោតលោកជរាប មកលះ បាបលោភបុណ្យចេញធន់ធាន ។ ទិញប្រេងអុបគ្រប់ឋាន តាមទន្លេ ទុកឲ្យគេអ្នកដើរក្នុងជលឋាន ដល់ពេលយប់នឹង ដឹងទីដែនឋាន ចេញចូលបានឥតមានក្តីបែងវែង ។ គោម នោះសោតឆេះនៅជាប្រក្រតី ដល់រាត្រីទើបឃើញភ្លើងភ្លឺខែង ដល់ពេលថ្ងៃពុំយល់ព្រោះសូរ្យសែង គេចាត់ចែងថែមប្រេង ១០ថ្ងៃម្តង ។ ខ្ញុំយល់ៗសរសើរលោកបារាំង លោកមក តាំងអុបគោមភ្លឺកន្លង ប្រាជ្ញាទុកជាទានឲ្យអ្នកផង បានដើរ ឆ្លងឃើញភ្លើងជាសញ្ញា ។ ឱស្រុកខ្មែរតាំងតែពីនេះទៅ មាន តែសុខឥតសៅឥតទុក្ខា បានបារាំងលោកតាំងគ្រងរក្សា តែង សីមាកម្ពុជាឲ្យពណ្ណរាយ ។ តែត្រឹមទីទន្លេជាស្ថានស្ងាត់ មកចេះចាត់អុបភ្លើងប្រចាំហ្មាយ រាស្ត្រទៅមករកស៊ីតាមស្រុក ឆ្ងាយ ដើរសប្បាយមិនតោងវង្វេងផ្លូវ ។ ឱទន្លេតាំងតែពី

បូរាណ មិនដែលមាននរណាបំភ្លឺចៅ ឥឡូវផ្ទុះមកបានបាំង
នៅ ឲ្យអុបគោមទូទៅទាំងគង្គា ។ សែនរុងរឿងភ្លើងហើយ
ទន្លេសាប ពីនេះទៅជរាបឥតភ័យា ឱរាត្រីយប់នេះជួនវេលា
ខ្ញុំនិទ្រាពុំលក់ជាទុក្ខក្រៃ ។ បែទៅទិសបូព៌ាឃើញរស្មី ព្រះ
រង្សីអារុណរះសែងប្លៃ ពួកកប៉ាល់ក៏ភ្ញាក់ឡើងទីទៃ ស្រាវយុថ្កា
វៃៗ ថយម្នីម្នា ។ កប៉ាល់គ្រឿនលឿនចូលទៅតាមព្រែក
ណាបង្អៀតក៏ជ្រែកបែកជាធ្លា តែកុងកាប់បទតាមទឹកគង្គា មើល
ព្រឹក្សាដុះហែតាមក្បែរផ្លូវ ។ ខ្លះដើមខ្ពស់ល្អូតលាស់ខ្នែងលំ-
ពង់ ខ្លះទាបទឹកលិចបុងឃើញខ្មៅៗ កោតប្អូឈើរតាមធន់
ណាស់ទៅ ទឹកលិចនៅ៥ខែប្រែមិនក្ស័យ ។ ឱព្រៃអើយ
ព្រៃដុះជារនាម ខ្លះជារាមស្បាតជិតបិទសែងប្លៃ ខ្លះខ្ពស់ស្រោង
ផុតទឹកពន្លឹកក្រៃ សត្វអាស្រ័យជាស្ថានសម្រាននៅ ។ កប៉ាល់
បើកលុះដល់គន្ធាយគម ឃើញភ្នំក្រោមនៅខាងឯលិចផ្លូវ ឱ
ភ្នំក្រោមតូចល្អមមានមនុស្សនៅ មើលៗទៅពុំឃើញមានដើម
ឈើ ។ ជាភ្នំដីលត្រងិលមានតែស្មៅ មានដើមពោធិ៍១នៅ

កំពូលលើ ក្រោយពោធិ៍មានវិហារគេទើបធ្វើ វត្តនោះតើលោក
ណាសទ្ធាសាង ។ ឯក្រោយធ្លាវិហារមានប្រាសាទ វិចិត្រ
ស្អាតដោយថ្មកជាប្រាង្គណ៍ ជារបស់បូរាណលោកសំអាង
ទំនងយ៉ាងបញ្ចុះព្រះធាតុក្សត្រ ។ ឬជាទីដំកល់ព្រះបដិ-
មា សម្រាប់អ្នកសាស្នាឡើងប្រដិបត្តិ ឱប្រាង្គណ៍នេះលោក
ណាមកបែងចាត់ មាននៅស្ពានបង្ហាត់ខឿនខ្វាត់ខ្វែង ។
តិឡូផ្ទះជុំរុតទ្រុតទ្រោមធ្លាយ ថ្មរសាយតាមជាយជើងកំផែង
ស្តាយអើយស្តាយប្រាសាទប្រសើរស្តែង បានលោកណាចាត់
បែងជួសជាថ្មី ។ មើលប្រាសាទលើភ្នំស្មើយំស្តាយ មិនគួរមក
អន្តរាយខ្វាយដោយដី ស្តាយតែស្នាដៃធ្វើស្មើកោសី មិនគួរបី
បែកបាក់ធ្លាក់ធ្លាយធ្លុះ ។ ខាងជើងភ្នំមានវត្តលោកសង្ឃនៅ
មានផ្លូវឡើងទៅខាងវត្តនោះ ឱភ្នំនេះស្តាប់ទៅយល់ពិរោះ
សញ្ញាឈ្មោះភ្នំក្រោមល្មមមានអាង ។ ព្រោះភ្នំគេសឹងតែនៅ
ខាងលើ មានដើមឈើដុះលើឃើញប្រឹងប្រាង ភ្នំមួយនេះមក
តាំងនៅក្នុងបាង មានទីអាងយ៉ាងនេះជាសាក្សី ។ បានជា

ហៅភ្នំក្រោមព្រោះក្រោមគេ នៅខាងជាយទន្លេអ្នកធ្វើត្រី តទ្យូវ មានអ្នកស្រុកនៅប្រក្រតី ដាំឬស្សីផ្ទិងស្លាបម្ការបេក ។ ឱភ្នំ នេះជាទីពីបូរាណ សមជាស្ថានសំណាក់អ្នកវិវេក ធឹកសរសើរ ប្រាសាទប្រសើរពេក ខ្ញុំក្រឡេកមើលទៅទីឧត្តរា ។ ឃើញ ទីតាំងតាំងបតនៅរៀងរាយ ប្រហាំទូបក្ករក្លាយកៈសាយណា ទូកគែហៅវ៉ែតមួងភាពផាយម៉ា ក៏ដឹងជាព្រះទីតាំងព្រះបក្រី ។ ហៅភ្នាក់ងារត្រួតត្រាព្រះទីតាំង ឲ្យបតតាំងតាមបៃរបុងព្រែកឬ ទូករាជវង្សបតក្នុងទូកកុង្ស៊ួយ ក្រុមមន្ត្រីបតអមលោមក្រោល្លា ។ ទូកអស់នេះទ្រង់ឲ្យមកប្រហាំ មុនទម្រាំព្រះបរមរាជា ដល់ ១០ កើតថ្ងៃសុក្រស្ដេចលីលា យាងដោយរាជនាវិកប៉ាល់ធំ ។ លុះកប៉ាល់រាជការស្រុកព្រះជំបង ទៅដល់ដងវាលវែងជាបុង ភុម លោកឲ្យបោះយុថ្កាបតប្រជុំ អ្នកជំនុំនាំគ្នាមើលត្រៀប ត្រា ។ លុះកប៉ាល់បតស្រេបលេចទូកបី ក្រុមមន្ត្រីសៀមរាប ទីឲកញ្ញា មកទទួលលោកធំជាតិស្សូរា បីគេបកភាសាបែង ការផង ។ លោកកុម្មីសែរអធ្យាស្រ័យតាមហេតុ ចាត់ឲ្យលោក

ចៅហ្វាយខែត្រព្រះដំបង នៅកប៉ាល់ឯក្រោយចាំរាប់រង ទទួល
អង្គប្រាស់ប្រងស្ដេចយាត្រា ។ តែខ្លួនលោកនឹងលោកសង្ឃបី
អង្គ ពុំរារង់បុះទូកអ្នកទកញ្ញា ខ្ញុំបាទឯងជាបារិលោកមេត្តា
ឲ្យយាត្រាទៅមុនដោយកំសាន ។ ទើបជញ្ជូនហិបពូកដាក់
ទូកស្រែប មួយរំពេចក៏ចេញតាមជលស្ថាន ពួកកំណែនកែន
បែរខំបែរប្រាន កាត់ត្រង់ដានទីជ្រៅទឹកព្រែកជីកថ្មី ។ បែរឯប
រ៉ែអបខាងព្រះទីនាំង ខ្ញុំក៏តាំងលួចគន់មើលស្រីៗ ពួកអ្នក
ក្នុងតែងអង្គល្អប្រិមប្រិយ៍ ឆវីភ័ក្ត្រហាក់ស្រីទេព្វកញ្ញា ។ សឹង
ប្រដាប់សង្វារចាខ្សែដៃ ទំហ៊ៀផ្សៃវិចិត្ររ័ពនា ៗទិមពេជ្រលេច
សែងព្រះសុរិយា សុកានកែវកាញ្ចណាប៉ព្រាតព្រាយ ។ ស្លៀក
ខៀនខាត់រ៉តអេរខំម៉ាស៊ី ផាត់ឆវីគន្ធរស់ពិគោរសាយ ខ្លះតែង
តួសុភាពភាពសៀមក្លាយ ខ្លះតែងកាយអាវសាយក្លាយបារាំង។
ពួកសាវឡឹកង្វូតទឹកប្រឡែងគ្នា សើចហោហាហៃលខាងព្រះទី-
នាំង ខ្លះមិនខ្លាចអំណាចពួកក្រុមវាំង ក៏សើចខ្លាំងលើសគេ
រេតែខ្លួន ។ ខ្លះអង្គុយស៊យសក់កញ្ចក់ខាង ខ្លះសំអាងសម

អ្នកស្រុកតែងធ្លាមាគាល័យ ដោតទង់ជ័យរាយរៀងតាមមាត់
ច្រក ខ្លះតែគូប្រទ្យ៉ាប្រដាប់ដក ពោះកំប៉ុងពែងបកអុបសំ-
អាង ។ គន់អ្នកស្រុកសៀមរាបសុភាពគួរ នៅជាជួរដង
ស្ទឹងទាំងសង្ខាង ស្ទឹងក៏តូចប្រាំងក៏ទាបជាភាពបាង ទទឹង
យ៉ាងបីព្យាមប្លាយប្រាកដ ។ រយៈផ្លូវទៅពីបុងភ្នៀសឯង ដល់
កំផែងសៀមរាបលោកកំណត់ បានបីរយកៅសិបប្រាំសិនគត់
លោករាស់ទុកជាបទបែបលាយវែង ។ តែខ្ញុំចេញចាកទី
កន្លាយគម ថ្ងៃទៀបត្រង់ក៏លួមដល់កំផែង បែរចូលបតឯប
ស្ពានភ្នាក់ងារតែង ត្រង់កន្លែងសានខ្វែងត្រើយខាងលិច ។
ពួកបារីបោយេក្ខនក្ខយជួយគ្នារើ ទ្រព្យរបស់ដាក់លើគោករំពេច
ខ្លះក៏មានតែទៃនឹងបង្ខិប ក៏ស្ពាយគេបឡើងគោកជ្រិកគ្រឹ-
ហា ។ ពោយពារាំងតាំងរៀបគ្រឿងលើគោក ចាំមើលលោក
នៅទីខាងផ្លូវថ្លា រង់រវេះកំណែននឹងលីលា ឡើងទៅតាប្រា-
សាទនគរវត្ត ។ លោកឧកញ្ញាស្មៀនត្រាសន្ធាបុណ្យ មកនិ-
មន្តលោកសង្ឃទៅផ្ទះគាត់ ចាត់បង្ហាន់ប្រគេនតាមកិច្ចវត សំ-

នឹងយួនកើតច្បាំងគ្នា សៀមជានារ៉ាប់រងសង្គ្រាមយួន ។ លោកចៅឃុនបឹតនាយបង្គាប់ ជាមេទ័ពលើកចេញមកតាមក្បួន ទើបឲ្យកកំផែងប៉មម៉ាំមួន ចាត់ជាក្បួនបន្ទាយការស-ត្រូវ ។ តាំងមកដល់រាជលោកអង្គរយ៉ែម លោកសមសែមចាត់បែងតែងតាំងនៅ កាលណោះឯងកំផែងសុខតតសៅដល់តទ្រូវត្រូវដែរាជការថ្មី ។ លោកឲ្យរើទៅវាយដាក់ផ្លូវផ្លាសម្រាប់ឲ្យមនុស្សម្នាដើរប្រក្រតី ខ្ញុំគិតៗអនិច្ចំទាំងបូរី តែទឹកដីគង់ដល់ផ្លូវអនិច្ចា ។ ឱស្រុកសៀមរាបជាភាពចាស់ សឹងខ្សាប់ដាសមិនថាទីត្រង់ណា អ្នកនឹងរកប្រយោជន៍ស្រែចំការនឹងបានផលប៉ុណ្ណារក្សាកាយ ។ មួយសង្ស័យនឹងស្រុកសៀមរាបនេះ បូរាណរិះឲ្យឈ្មោះខុសបរិយាយ ស្រុកខ្មែរទេម្តេចគេយកសៀមលាយ តាមបរិយាយសារតារដីរ៉ាមាន ។ កាលព្រះបមបក្រីត្រីនេត្រក្សត្រ គ្រងសម្បត្តិឥន្ទ្របតបូរីស្ថានគឺនគរធំនៅជាប្រធាន បមក្ស័ត្រក្សាន្តមានបុណ្យលើសនានា ។ មានព្រះនេត្របីភ្នែកប្លែកជាងជន នេត្រកណ្តាលតែគន់មើល

នរណា អ្នកនោះឯងក៏ដល់ក្ស័យជីវា ពួកភារាក៏ស្ញែងក្រែង បារមី ។ លុះណោងស្នោគីសៀមជាសួយទឹក កជាសឹកលើក មកវាយបូរី ដល់មកទីត្រង់នេះបោះយោធី តាំងជាទីសមរៈ ភូមិ៍ជ័យ ។ គ្រាន់ជ្រាបដល់ព្រះនរិន្ទ្រពិនក្រស័ត បមឥន្ទ្រប័ត ក៏ទ្រង់ព្រះក្រោធក្រៃ ទើបលើកពួកបតុះង្គក្នុងរៀងជ័យ ចេញ តដៃពៃរីទ្ធហាន ។ មកដល់ស្រេបស្តេចបើកព្រះនេត្រកែវ តែ មួយប្លែវត្រូវសៀមស្ងៀមមិនបាន បោលអាវុធបាកដៃលុត ក្រាបក្រាន វាបពុំហានតរិទ្ធ៌រត់វិញទៅ ។ ហេតុដូច្នោះបាន ហៅថាសៀមរាប ព្រោះមានភាពសៀមខ្លាចព្រះបមបៅ ឬ-ភាណរាជបារិកតាំងនាមនៅ ដល់ឥឡូវសៀមប្រែហៅសៀម រ៉ាត ។ ពាក្យសៀមរ៉ាតប្រែថាសៀមគតក្រែង តាំងសំដែងឥទ្ធិ វិទ្ធិ៍គិតប្រមាទ ដើរទន្ទ្រានរានរុកសីហានាទ មិនក្រែងជាតិ កម្ពុជាវេលានោះ ។ ព្រោះស្រុកនេះជាស្រុកឡើងសៈយ៉ាម សៀមធ្វើតាមអំណាចឥតខ្លាចសោះ ពាក្យ"រ៉ាត"សព្វនេះប្រែ ដូច្នោះ បើរាដ្ឋៈវិញនោះថាដែនស្រុក ។ ទំនងយ៉ាងសៀមប្រើ

·ដ្ឋ, ជាខ្យល ប្រយោកដល់ត្ល·ត, តាំងជាមុខ ខ្ញុំពីគ្រោះសព្ទ
វ៉ាតឧបាតទុក តទ្បូវស្រុកបានមកខ្មែរវិញហើយ ។ គឺបាន
ដោយអំណាចរាជនិវេស ក្រុងបារិសយើងតាំងជាកោះកើយ
សៀមបាងកកល្បកមកមិនបានឡើយ យើងបង្កើយសៀមវ៉ាត
ហៅសៀមរត់ ។ ព្រោះកាលសៀមប្រគល់ទឹកដីឱ្យ ត្រឡប់
ក្រោយវិលទៅបាងកកហ្មត់ ហេតុនោះគួរពួកយើងបោះប្រាកដ
សន្មតហៅស្រុកសៀមរត់វិញ ។ ពណ៌នាសៀមរាបគាប
សៀមវ៉ាត សែនអាណាចនឹកឡើងគួរតែម្នេញ ព្រោះពីដើមបុះ
យួនជូនសៀមវិញ តទ្បូវពេញដូចអុនគុណបារិស ។ អើ
ស្រុកខ្មែរកែមុខបានសុខសាន្ត ព្រោះរូបស្ថានភ្នំពេញរាជនិវេស
កិត្តិយយស់សុះសាយទូប្រទេស បារាំងសែសវិសេសជាបិតា ។
មួយដូចយ៉ាងប្រាសាទនគរវត្ត បូរាណក្សត្របាត់សាងក្នុងសេ-
មា យូរអង្វែងពុំបែងជារាជណា ទៅជាព្រៃព្រឹក្សាស្វាវ៉ានៅ ។
ពុំមានលោកឯណាជួសជុលបាន ពោលជាស្ថានសមសាន
សែនហ្មងសៅ ដល់តទ្បូវបានលោកបារាំងនៅ លោកបាត់

ផ្លូវជួសជុលរីប៉ុល្លា ។ ពណ៌នាបាតតិបលេបរទេះ ព្រមទាំង សេះជុំនីសលោកតស្សរ៉ា បរមកដល់របស់បួលម៉ីម្នា ខ្ញុំនាំគ្នា ផ្តុករបស់ហើយបរទៅ ។ លោកកុម៉្មីសែរជិះសេះបរទៅមុខ ពួកអ្នកស្រុកនាំគ្នាមើលខ្លួលខ្មៅ ពួកខ្ញុំបាទដើរឃុំរទេះទៅ បរ តាមផ្លូវខ្សែលួសលោកជួសថ្មី ។ ព្រះទិនករបរបែអារុណរែង កាំដៅសែងព្រះអាទិត្យរិទ្ធិរង្សី ពួកអ្នកដើរសែនក្តៅសៅធរ៉ា ញ៉ារ ឥន្ទ្រិយញើសស្រោក់ប្រឡាក់កាយ ។ អនិច្ចាតែខ្ញុំគ្មានឆ័ត្រ បាំង ត្រូវកំឡាំងព្រះអាទិត្យរិតក្រហាយ ឯណាទុកនឹងនឹក ដល់ឆោមឆាយ សេចក្តីហ្មាយឆ្ងាយមាសនិវាសមក ។ ស្តាយ អើយស្តាយកាយកែវកន្និដ្ឋ មកផងរ៉ាទឹងនាំមើលប្រកល្ហក ឱដើមរោគជួបរោគរាគរិតរក ហៅដើមធ្លកមិនធ្លាប់មកឯកា ។ គន់ព្រឹក្សាលតាដុះដោយព្រៃ ខ្លះល្អូតលៃលំពង់ទ្រង់ផ្លែផ្កា ស-កុណ្ណជាតិហើរចារបេុងសាខា ចឹកង្កែហាសត្វស៊ានអាណែក ក្រៃ ។ ភ្មូមរីហើរត្រង់កន្លង់បរ គ្រេបកេសរបុប្ផាពនាល័យ សត្វហ្វាំងៗទ្រហឹងកណ្តាលព្រៃ ប្រឡំសត្វរោរែបន្លឺសៀង ។

សែនស្រណោះសព្ទសេករីរេកបិត្ត ទំប្រជិតសាលិកាជាគូគៀង កោកីលោលោតលេងទំរវៀង បញ្ចេញសៀងភ្ញាំងក្រាំងក្រអៅ ។ គន់ចំបក់ដូចបងចំបែងពិត្ត ចៅដើមខ្វិតដូចបងមកខ្វែងចៅ ឱដើមសោកដូចបងមកសោកសៅ ដើមស្រឡៅនៅស្រឡាញ់ចេញចោលមក ។ ឱដើមប្លាញ់គេប្លាប់លាបដំបៅ ដើមស្រឡៅធ្វើបៃវត្តរកប្បណ៌យក ធ្លកអើយធ្លកមិនធ្លាក់ផ្លែបុះមក ខ្ញុំនឹងយកធ្វើប៉ុយបង្ហុយពោះ ។ គន់ដើមយាងរាងយោរយោកដោយខ្យល់ គេកប្បណ៌ដុតយកជ័រធ្វើបន្ទះ អតិប្វាដើមយាងម្តេចយ៉ាងនោះ ឲ្យគេបោះទាំងស្រស់ដុតដូច្នេះ ។ យ៉ាងអើយយាងចៅសាងកម្មយ៉ាងណា បានជាមកវេទនាឲ្យភ្លើងឆែះ ឈើឯទៀតមិនដូចឈើយាងនេះ បើតាមរិះឈើនេះបុះតំរា ។ សមណះមានទ្រព្យសិកាក្លួន ស្រីមានខ្លួនប្រុសក្លួនដោយកាមា ព្រឹក្សាជាតិយ៉ាប់យ៉ុនព្រោះផ្លែផ្កា ត្រីអាំងមានទើបឆ្នាមកយាយី ។ យ៉ាងឯងយ៉ាប់ព្រោះមានជ័រទឹកនៅបានជាត្រូវកំដៅព្រះអគ្គី ឈើឯទៀតឥតជ័រគេរុំខ្លី គ្មាននរណា

យាយីដូចយាងឯង ។ ឱព្រឹក្សាត្រូវការមិនថាអ្វី កើតសម្រាប់
ផែនដីប្រាកដស្ដែង ដូចរូបកាយសង្ខារគេតុបតែង មិនផុត
ការគ្នាឯងតែងអាស្រ័យ ។ ឱព្រឹក្សាលតាតាមប្លែកៗ បូរាណ
បែកបេះឲ្យឈ្មោះទីទៃ កោតហ្ន៊ុំលោកបូរាណបេះកែខៃ ឲ្យតាម
សព្វឈើព្រៃគ្រាន់កំណត់ ។ រយៈផ្លូវទៅពីសៀមរាបឯង ដល់
កន្លែងមុខតាគនគរវត្ត បាន ១៤០ សិនទៀងទាត់ សេស ៥
សិនសន្មតិកត់មាត្រា ។ លុះដើរដល់ជ្រៃធំត្រសុមម្លប ប-
ប្លួលគ្នាចូលឈប់ម្លប់សាខា សម្រាកញើសរំហើយដោយវាតា
ព្រះសុរិយាជ្រៃសែងឱនោទ័យ ។ ទើបនាំគ្នាបរលីបាកទីនោះ
ភក្ត្រាឆ្ពោះដម្រង់ត្រង់ដល់ឮ មន្ទីរឬលោកតាំងជារាំងជ័យ
សម្រាប់ទីក្សត្រថ្លៃព្រះទ្រង់ស័ក្តិ ។ លោកស័ក្តិបីស្តីទីព្រះអាជ្ញា
ជាផស្សរាក្នុងការព្រះដំណាក់ ហៅហ្វាយខែត្រសៀមរាបបំរុង
ស័ក្តិ ទទួលភ្នាក់ងារកេណ្ឌរាស្ត្រតែងផ្លូវ ។ ហៅហ្វាយខែត្រ
ព្រះដំបងរ៉ាប់សំអាង កេណ្ឌពួកជាងវបនាការក្នុងក្រៅ ហៅ-
ហ្វាយស្រុកគ្រប់ខែត្រគ្រប់លំនៅ សឹងចុះត្រូវកំណែនការទីទៃ ។

គឺឧកញាស្វាយបេកបំណែកមុខ នឹងឧកញាភ្នំស្រុកខេត្រជើងព្រៃ រួមឧកញាសួរ្យសក្ដិសោភណាក្រៃ ត្រូវធ្វើព្រះពន្លាជ័យដំណាក់ធំ ។ កណ្ដាឧកញាក្រឡាញ់បញ្ចលមុខ រួមឧកញាខេត្រស្រុកសូទ្រនិគម ត្រូវរោងខោលរោងសែកបែកតាមមុមឯរោងបៃវអមជុំត្រូវកាំបាញ់ ។ គឺស្រុកពួកស្រុកមោងស្រុកត្បោតផង ទាំងទឹកជោរបាត់ដំបងមង្គលបូរី ឯឧកញាមង្គលធរនិន្ទប្តី ត្រូវបើកត្រីអង្ករបែកគ្រប់កង ។ ចៅហ្វាយខេត្រសៀមរាបនាយកំណែន ឲ្យកោះកណ្ដារទែះជាងរយហោងកណ្ដាទូកធំ ៥០ មាននាយកង ចាំរាប់រងចូលចេញខាងជើងទឹក ។ កណ្ដាគូលី ១០០ ប្រចាំនៅ តែការដល់គេហៅចុះបៃវត្រឹក រាស្ត្រសៀមរាបរវល់ខ្វល់ពន្លឹក ទាំងជើងគោកជើងទឹកបេញគ្រប់ដាន ។ ខាងការល្ហាស់កណ្ដាសែះ ៥០ ព្លាយសម្រាប់នាយ ៗ ដើរពុំបាន ទាំងរថាសារបីព្រះរាជយាន ប្រចាំរ៉ាប់ក្សត្រក្សាន្តស្ដេចយាង់ដល់ ។ ពួកក្រមាររចាត់ការព្រះពន្លាសឹងប្រក្លតអ្នកគ្នាគ្រប់មណ្ឌល់ ជ្រើសតែជាងស្ទាត់ ៗ ហាត្ថ

កោសល់ ធ្វើមិនធ្វល់ក្នុងការដំណាក់ថ្មី ។ ឯរោងលោកកុម្មី-ស្សែរតាំងខាងស្ពាន មានទាហ៊ានតាំងរានចាំប្រែកតី បន្ទាប់តរោងផ្ទុមក្រុមមន្ត្រី កណ្ដាលលោកស័ក្ដិបីរាជអាជ្ញា ។ ចុងខាងត្បូងគឺរោងលោកចៅហ្វាយ ព្រះដំបងតាំងរាយប្រជិតគ្នា លោកស័ក្ដិបីនាយត្រួតលើព្រះពញា ឲ្យកែណ្ណតាមយស្ណាបណ្ដាស័ក្ដិ ។ សឹងប្រដាប់ឈើស្រស់របស់ព្រៃ ក្រងជាភ្លួងមាលៃបំពេនពាក់ ចងសំយុងជាភ្លួងរបៃថ្នាក់ កែមចំម្លាក់មើលចម្លែកភ្នែក លាកិយ៍ ។ ឯពួកចិនតែងខាងហាងដាក់ផ្សារ មានទំនិញសព្វប្រការគ្មានខ្វះអ្វី ខ្លះតាំងរានលក់ភោជន៍ភ័សបំណើ ស្លាបារីកាហ្វៃតែនុំបុាំង ។ ខាងពួកខ្មែរអ្នកស្រុកលក់បេកស្មោរ នុំបាក់កោរនុំជាលន្សូវនុំបុាំង ខ្លះក៏លក់នុំបញ្ចុកលតបាយអាំង ខ្លះក៏តាំងរានមីរានសុរា ។ បណ្ដាពួកអ្នកទៅនគរវត្ត ពុំមានអត់នឹងស្បៀងសៀងជីវា មានតែប្រាក់ក៏ទិញបានភោក្ដា សែនមហាលោះលាយសប្បាយក្រៃ ។ ដោយទីនោះធ្លាក់ទៅជាសមសាន លោកមករៀបជាស្ពាន

ព្រះរាំងជ័យ មើលសព្រាតភ្លឺជ្រះដាសទាំងព្រៃ ហាក់មឿង មានក្សត្រថ្លៃគង់ប្រក្រតី ។ ឯខាងពួកបារាំងតាំងសាងតឹក មើលភឺលឹកប្រកសឹងស័ង្គសី ផញាំងលាបបាយអពណ៌លឿង ខ្ចី គ្រឹះពីដីផ្ទៃស្មើល្អបវរ ។ ផ្ទះនោះឯងបែងភ៉ារ៉ទីប្រជុំ លោក គួរែរណើរជាធំព្រៃនគរ លោកអញ្ជើញមកដោយក្តីសាទរ សមោសរាជការនគរវត្ត ។ ខ្ញុំបាទយល់ទីស្ថានលោកតែងថ្មី នឹកសរសើរបារមីព្រះបមក្សត្រ គ្រាន់តែយាង ១ គ្រាក៏កើតបាត់ ទីព្រៃស្ងាត់ក្លាយកើតជាវាំងស្ថាន ។ ឱព្រះគុណប្រកបដោយ បុណ្យក្រៃ លើសនិស្ស័យយើងពុំប្រមាណបាន ខ្ញុំឱស្សាហ៍ យាងមកទីបូរាណ ឲ្យព្រៃប្រែជាស្ថានបូរីគន៌ ។ មើលក្រសិន្ធុ យល់ក្រសែជលេសាយ វាលវែងឆ្ងាយឱបអមនគរវត្ត ។ លោក ជីកធ្វើជាគូរាំងស្អាតស្អាត់ មានបង្ហាត់ខឿនខណ្ឌខាត់ពៃរ៍ ។ គង់គង្គាក្រសិន្ធុវែងរវឹង ខឿនសុទ្ធសឹងថ្មជាដាសនាទី ធ្លាក់ ជារូបក្បាច់ហូតហៀនពេជី ជណ្តើរកាប់ក្បាច់ភ្ញីងកប់ន្តបែង ។ កណ្តាលឋានមានស្ពានថ្មដាដាស បំនួនក្រាស់ជាងសិនសែន

គួរស្វែង តែកំណាត់ទទឹងនឹងប្រវែង មានក្នុងក្បួនល៉ាយថែង លោកថែងទុក ។ ខាងចុងស្ពានមានផ្លាជាបីផ្លូវ មានរូបតោឈរនៅគ្រប់មុមមុខ តោសិលាខ្លះនៅពុំទាន់ពុក ខ្លះបែកមុខបាក់ក្រញាំពីការកាយ ។ អនិច្ចាតោថ្មលោកកសាង មើលឋាឋាងយ៉ាងរស់ស្អុះប្រៃប្រាយ ឥឡូវមកធ្លាយធ្លាក់បាក់ខ្ទាត់ខ្ចាយ ស្តាយអើយស្តាយមិនគួរមកពីការ ។ មានអ្នកទ្រោបង្រៃឥតគំ-និត ទៅសំលៀងកាំបិតគ្រឿងប្រហារ ឲ្យខូងខូបខាតសាប់បង់អសារ មិនស្តាយការស្នាដៃបូរាណសោះ ។ ឱតោអើយតោឈរមិនមើលមៀង មកឲ្យគេសំលៀងខ្នងតោបុះ ម្តេចមិនទឹងខាំវាសំលៀងនោះ ឲ្យវាលុះក្តីមរណ៍យវាទៅ ។ អាណាអើយបំផ្លាញរូបតោលោក គ្មានប្រយោគឲ្យយល់ការវាក់ជ្រៅ គួរឬលោកខំសាងតាំងទុកនៅ មកសត្រូវបំផ្លាញរបស់លោក ។ គន់ ៗ ស្ពានស្ពានថ្មតប្រដិត ជាក្តារថ្មជាសដិតប្រកិតគោក ទោះដំរីបរជាន់ក៏គ្មានយោគ ឥឡូវជ្រោកស្រុតខ្លះតែដើរបាន ។ ប្រកាន់ដៃខ្មែរូបវាសុក្រឹ ដប់សិរសីដូចស្និតជិតជុំប្រាណ លើក

ពពាទ្បើងពភ្លាក់ហាក់ហៅហាន សំដែងប្រាណប្រួញរូបជា
មួយគ្នា ។ មើលនាគរាជអង់អាចអំណាចស្វែង ខ្លួនក៏វែង
ក្បាលក៏វក់តាមទ្វារ លូនលើស្ពានមានជើងកល់គង្គា កន្ទុយ
បែកញែកគ្នាតាមផ្លូវ ។ ឱរូបវាសុក្រឹតតក្រែងគ្រុឌ តាំង
សម្តែងរិទ្ធិវិទ្ធតសត្រូវ ប្រសិនគ្រុឌមកយល់យ៉ាងពុំនៅ គង់
ស្លុះទៅជ្រកក្នុងក្រសិន្ធុនេះ ។ ឆាគអើយនាគបាសាណបូរាណ
សាង ពីដើមយុាងល្អឯកដូចម្តេចឯះ ឥឡូវនាគងាកធ្លាក់បាក់
របេះ ឃើញតែរាងយ៉ាងនេះអស់លំអ ។ ខ្លួនក៏ឃ្លាតក្បាលក៏
ឃ្លៀងទៅដោយខ្លួន ឃើញតែក្បូនជើងទៀនប្រចាំទ្រ ស្តាយ
អើយស្តាយស្នាដៃលោកតែងម មិនតាំងតថាវរៈឲ្យវែងទៅ ។
ឱអនិច្ចាសង្ខារនាគាថ្ម ហ្មាយតស្និតស្នេរបោរកាលនៅ នេះពុំ-
ទាន់ប៉ុន្មានមកហ្មងសៅ មករុសរាយធ្លាយទៅទីទៃផ្តាស់ ។
មែនហ្ន៎សព្វសង្ខារក្នុងលោកិយ៍ មិនថាអ្វីតែកើតមកគង់វិនាស
បុះត្រៃលក្ខណ៍ផាក់យ៉ាងពុទ្ធប្រកាស សង្ខារចាស់គង់ផ្តាស់ទៅ
ទីទៃ ។ អម្បាល់ថ្មគង់ប្រែះបែះបាន បំណាច់បើរូបប្រាណយើង

សព្វថ្ងៃ នឹងមានជាតិខ្លឹមសារឯណានៃ គង់បន្លែដោយដៃ រោគបិទ្ធា ។ កើតជាកាយគង់ថ្លាយសូណ្យ៍ជីវី បំពេញព្រះ-ធរណីតែរាល់គ្នា គួរនឿយណាយបង្អន់ភ្លើងលោភា យក នាគានគរវត្តសង្កត់កាយ ។ ខ្ញុំពិនិត្យគិតផ្លូវព្រះត្រៃលក្ខណ៍ ចិត្តមិនធ្លាក់ឲ្យបំអារម្មណ៍ហ្មាយ នៅតែស្ទុះម្តង ៗ ដល់ឆោម ឆាយ ព្រោះឃ្លាតឆ្ងាយក្រែងឃ្លៀងលំអៀងទៅ ។ ឱចិត្តខ្ញុំ លោកិយ៍ដូចពានរ មិនដែលឈឹងនឹងឈរឲ្យនឹងនៅ ឃើញ ឯណែះនឹកឯណោះមិនបុះផ្លូវ ហាតែក្រៅក្នុងមិនត្រេបភ្លេបក្តី ត្រេក ។ លុះដើរដល់រោងទងខ្លោងទ្វារប្រាង្គណ៍ របៀងខាង យ៉ាងខណ្ឌកខ្សែងយ៉ែក តួកណ្តាលមុខដាប់ជា ៤ ប៉ែក មាន យ៉សែកបែកបុះជាពីរផ្លូវ ។ ប្រាង្គណ៍កណ្តាលមានរូបទេពសិ-លា គឺអ្នកតាមហារាជប្រចាំនៅ បួនព្រះករកាន់គ្រឿងភ្លឺសន្ធៅ មើល ៗ ទៅគួរសម្បើមស្បើមមុហិមា ។ ពួកអ្នកព្រៃរាប់អានជា ទេព្រក្ស យកក្រដាស់មាសប្រាក់អុបបូជា បន់អ្នកតាមហា រាជរឿងរិទ្ធា សូមឲ្យកើតលោភាស្រីសួស្តី ។ ខ្ញុំយល់រូបអ្នកតា

ហ័ត្ថាសាយ ទំនងព្រះនារាយណ៍ឡើងវ៉ង្សី ព្រោះបុរាណរាប់
អានព្រះសូលី ឥស្សរាធិបតីតាំងជាមុខ ។ ពួកអ្នកព្រៃពុំស្គាល់
យល់អម្ចាប តាំគ្នាហៅមហារាជទៅទាំងស្រុក ឱព្រះនារាយណ៍
ឡើងតេជវិសេសសុខ ផ្ចាញវិមារទសមុខបានសុខ ។ មើល
ជំណាក់ប្រាង្គណ៍ដាក់ព្រះនារាយណ៍ កំពូលបាក់ធ្លាក់ធ្លាយធ្លុះ
សុរិយា តឡូវមានគេធ្វើជាបញ្ហា ប្រក់ក្បឿងយើងធម្មតា
ការណ៍ផ្ទៀងខ្យល់ ។ ទ្វារខាងត្បូងមានគ្រឹះឫសជល់ដី បររទេះ
សាលីទាំងសកល ទោះជីវទាំងក្លបក៏តតទាល់ ប៉ុងផ្លូវជល់
មុខនាគជាដើមព្រាត់ ។ ផុតរោងទងរំលងខ្លោងទ្វារប្រាង្គណ៍
លោកសំអាងសាងជាកំផែងព័ទ្ធ តាមក្រសិន្ធុឡោមជុំគរវត្ត
លោកកំណត់ទ្វារចេញជា ៤ ដាន ។ ចូលទ្វារប្រាង្គណ៍ចេញ
ខាងទិសបូពា៌ មានថ្នល់ធ្លាទៅត្រង់មុខព្រះលាន លោកវិចិត្រ
ដោយថ្មកជាស្ពាន សង្ខាងមានរូបនាគប្រកាន់ដៃ ។ រយៈផ្លូវ
សិនមួយមានផ្លូវញែក ជាពីរប៉ែកបែកចុះទៅទីទៃ ដល់កណ្ដាល
មានប្រាង្គណ៍ខាងស្ដាំដៃ ពួកអ្នកព្រៃហៅថារោងក្រយា ។

ប្រាង្គណ៍ខាងផ្សេងគេហៅរោងកំណើ មើលគួរបើសមពាក្យអ្នកព្រៃថា មានផ្លូវចុះពីថ្នល់ដល់ដូចគ្នា តែឥឡូវទៅជាព្រៃដុះជិត ។ រោងព្រះស្មោយធ្វើដោយសិលាភ្នំ តាំងជាមុមមុខបីជាបីស្និត ឥតកំពូលមានដំបូលលោកវិចិត្រ យ៉ាងសង្ខិតឥតភឹនភាពស្មើផ្ទៃ ។ ឱរោងគ្រូមិនគួរមកផ្ទុះធ្លាយ បាក់ខ្ទាត់ខ្ចាយអន្តរាយដោយពួជ្រៃ គ្រាន់នឹងចូលទៅមើលក៏ស្តុកក្រៃ សែនអាល័យស្តាយរោងខូចអសារ ។ លុះដើរដល់មន្ទល់ផ្ទះបារាំងលោកមកតាំងកសាងប្រាង្គណ៍ឬជា ឈ្មោះមោនសៀរកុម្ម៉ៃជាមេការ ចៅភ្នាក់ងារទទួលផ្ទួសប្រាង្គណ៍ស្ថាន ។ លោកឲ្យជីកអាចម៍ដីដែលលុបថ្នល់ ដរាបដល់គ្រឹះថ្នល់ពីបុរាណ ឬឯណាដែលបាក់ធ្លាក់ចាកស្ថាន លោកឲ្យដាក់តាមជានសណ្ឋានចាស់ ។ លោកមោនសៀរកុម្ម៉ៃដៃបារាំង យកសីមាំងលាបផ្សាប់ដូចក្រដាស់ ឯណាស្លែហាប់ខ្លាំងមើលមិនច្បាស់ លោកឲ្យរោងបោសប្រាសសំអាតចេញ ។ ពួកគូលីស៊ីឈ្នួលផ្ទួលធ្វើការ កប្បូណ៌ឈើរឬជាដាក់ពាសពេញ

ខ្លះពោសផ្កាថ្មល់រលីងធិញ អ្នកចូលចេញមិនមានជិតធ្លី ។ ខ្ញុំដើរដល់យល់ថ្មល់លោកសំអាត ឃើញពួកជាតិខ្មែរយើងជាគូលី នឹកអាណិតជាតិខ្មែរក្រដល់ទី ទទួលការគូលីស៊ីឈ្នួលគេ ។ គន់រូបរាងទុពលពោះកំប៉េះ សក់ក្រញ៉ាញ់ខ្មៅក្រញ៉េះ ផ្អែះដូចភេ ទាំងស្លៀកពាក់សំពត់ក៏ខុសគេ ឱខ្មែរទេម្តេចខុសនឹងយើងម្លេះ ។ ឬពួកនេះជាជាតិសម្រែគួយ អ្នកងារស្លួយលេខវិត្តនគរនេះ ឬជាពួងរដែគេកែណ្ណងះ បានជាប្លែកយ៉ាងនេះគួរអនិច្ចា ។ លុះដើរដល់មណ្ឌលទីរាជហាល ថ្មីជាដាលក្រាលសឹងក្តារសិលា ផ្ទៃពីដីពេជ្ររួតត្របកផ្កា រៀបជាសា-រពើរត្បូត្រៃរួតថ្នាក់ៗ ។ មានសរសេរថ្មឈូកជាញកចេញតាំងជុំវិញមានក្បាច់រំលេចដាក់ មានជណ្តើរកាប់ឡើងជាថ្នាក់ៗបីប្រប័ក្ខឡើងចូលព្រះប្រាង្គណ៍ស្ថាន ។ ផ្ទៃរាជហាលកាលដើមពោះសំណា លុះតៗដល់យើងអន្តរធាន បាក់សំណានៅតែថ្មក្រាលជាលាន របៀបរាជរាបណែនសែនភិរម្យ ។ គន់ប្រាសាទស្អាតប្រសើរដំណើរប្រាង្គណ៍ កំពូល៥ប្អូនខាង

ខ្ពស់ត្រសុម ឋានរួតៗ រាល់ជាន់ជាពាន់ជុំ ប្រាសាទធំតាំង
កណ្ដាលត្រដោមដុង ។ រួតពីដីបីជាន់រោងទងជុំ របៀងមុម
មុខដាប់ក្បាច់រលង់ ជាហ្លួតហៀនវៀនរាំងកញ្ចាំងបុង ឈូក
សម្ប៉ាកឆែកសម្ប៉ុងជាខាន់ៗ ។ ក្បាច់រងស្បូវទេពប្រណម្យ
ដៃប្រណិត ល្អសប្រកបល៉ាយប្រិកិតភ្ញីរល្វីវន្ត បែរកាបាំងរកិត
ស្និតរយពាន់ របៀងខាន់របៀបខាត់ចាត់ស្មើគ្នា ។ ឱដាង
ឆ្លាក់រូបយក្ខធាក់ពានរ យុទ្ធនារីករិរជាកោលា រូបរាហូបៀម
ហៀនហង្សពាំផ្កា យក្ខទេវតាទាញព្រាត់វាត់គីរិន្ទ ។ មេក្រប
ទ្វារបង្អួចក្បាច់របេក លកក្របកផ្ចាប់មុខដូចគេមិន ផ្ទៃក្ដារផ្ដែរ
ឆ្លាក់រូបរាជទេវិន្ទ តយុទ្ធនឹងអាសុរិន្ទរាជបិត្រា ។ ជញ្ជាំងទ្វារ
ឆ្លាក់ជាទេពរបាំ ក្រាយលំនាំឈររាំក្បាច់កាច់ផ្កា ខ្លះបួងសក់
ខ្នក់បីចងជដា ខ្លះសំយាកកេសាសិតក្រពាំង ។ ខ្លះពាក់
មកុដកំពូលបញ្ចតរឹង្គ របៃមុខក្រឡឹងភាពកញ្ចង់ សូ៉ងកងអង្កន់
ព្រះហត្ថ ស្លៀកសម្ពុយថ្នក់បាំងក្រោមនាភី ។ បង្កេះរៀវជង្គង់
រ៉ាប់មួយក្ដាប់ដៃ មើលវិសេសសុទ្ធវីស័យសមឥន្ទ្រិយ៍ សុគន

ក្បុំសមក្បូននួនមាលី ភាពនរេតភេទនារីទីស្នេហា ។ មាន ប្រុសយើងភ្លើងរាគរាពោលខ្លាំង ទៅអង្អែល “មំសំ” នាងសិលា ឡើងរលង់សឹករលីងទាំងរូបា គេស័ញ្ញាហៅថាស្រីមាន លក្ខណ៍ ។ មើលមណ្ឌាល់រោងទងទំនងសុម ជញ្ជាំងជុំសឹង ជិតជាបម្លាក់ ជារូបរឿងរាមកេរ្តិ៍គីរាមលក្ស្មណ៍ ច្បាំងនឹងយក្ខ ក្រុងរាពណាសូរ ។ ស្វាប្រចាក់យក្ខប្រចាប់រ៉ាប់រងគ្នា ស្វាក្រទី យក្ខក្រទាកប្បណ៍ផ្លាស់ប្តូរ យក្ខប្រជិតស្វាប្រជាប់ចាប់កំពូល ស្វាប្រដាល់យក្ខដួលដេកក្បិនក្ប៉ុយ ។ គន់គំនូររឿងរាមសង្គ្រាម យក្ខ ជាអាណាក់មើលអណែកអនន្តក្រៃ ជ្រុងទក្សិណាគូរកាល សហស្សនៃយ គង់នៅឰក្រៃឡាស់វិមានប័ន្ទ ។ ក្រៃឡាសផ្អៀង ផៀងផ្លាក់ព្រះសូលី ប្រើក្រុងរាពណ៍អសុររាជកម្ពុន្ធ ដៃ ២០ អុខ ១០ រូបសកន្ធ ឲ្យជម្រង់ប្រាង្គណ៍បន្ទក្រៃឡាសស្ពាន ។ រាពណាគេរមិត្រវិទ្ធ័សាហ័ស ជម្រង់ភ្នំក្រៃឡាសឡើងត្រង់បាន ព្រះឥស្សរក៍ទ្រង់ព្រះរាជទាន នាងមណ្ឌោកល្បាណជាភរិយា ។ ផ្តែរខាងបូព៌ាគូរកាលសុគ្រីពយំ អង្វរអង្គព្រះបរមរាមា ឲ្យជួយ

ផ្លាញជីវិតនៃស្ដេចស្វា ក្រុងពាលីជេដ្ឋបច្ចាមិត្រ ។ ព្រះរាម
រ៉ាប់ហាប់ធ្នូបរប្លែងសរ បាញ់ពានរពាលីសូណ្យជីវិត គួរទាំងពួក
នារីស្រីស្នំស្និទ្ធ លោកអាណិតសែនអាណោចខ្មោចពាលី ។
ឯសុគ្រីពរិទ្ធិរុទ្ធបុត្រសុរិយា ក៏លោកនៅទៀបព្រះទែនទី
អញ្ជើញអង្គរាមាចូលធានី តាំងពិធីលើកសពពានរា ។
ឯផញ្ញាំងខាងត្បូងគួរព្យូហបាទ ដង្ហែអង្គនរនាថកេតុមាលា
លើកជាក្បួនព្យូហយុទ្ធនា គ្រប់ភាសាចូលពឹងព្រះបារមី ។
ខ្ញុំគន់មើលព្រះកេតុគេបិទមាស គង់លើអាសន៍កណ្ដាលពួក
សេណី សែនរុងរឿងថ្កើងបុណ្យព្រះចក្រី ជាអស្ចារ្យផែនដី
សកលអាយ ។ អង្គនេះឬគឺជាបឋមក្សត្រ គ្រងសម្បត្តិឥន្ទប័ត
វិសេសសាយ ទ្រង់សាងព្រះនគរវត្តដ៏ផើតឆាយ ស្ដេចលើក
ប្ហាយព្រះពុទ្ធឃោសា ។ កាលលោកទៅចម្លងព្រះគម្ពីរ អំពី
រាជធានីកោះលង្កា វិលមកដល់ប្រទេសខេមរា បមក្សត្រានិ-
មន្ត្រឲ្យលោកនៅ ។ លើកប្រាង្គណ៍នេះប្រគេនជាមណ្ឌល ទី
ដំកល់ព្រះគម្ពីរគម្ភាពជ្រៅ ពុទ្ធឃោសាចារ្យលោកគង់នៅ បាន

ជាហៅនគរវត្តដោយកំណត់ ។ ព្រោះប្រាង្គណ៍នេះពីដើមជា
នគរ ដល់ក្រោយទ្រង់សាទរថ្វាយជាវត្ត ពួកបូរីនាំគ្នាមកសន្ន-
មត្តិ ហៅប្រាសាទនគរវត្តតាមបទមាន ។ ឱព្រះគុណព្រះ
កេតុមាលាក្សត្រ ព្រះទ័យកាត់ពុំស្តាយព្រះរាជស្ថាន ថ្វាយជា
វត្តសុំរេបស្តេចចេញភ្កាន ទៅតាំងស្ថានព្រៃក្មេងបេងមាលា ។
ឥឡូវសូណ្យព្រះយសឈ្មោះបាត់បង់ យើញតែរូបព្រះអង្គគង់
ប្នុះណា ខ្ញុំបាទយល់សរសើរព្រះចេស្តា លើកហ័ត្ថាបង្គំ
គុណក្សត្រថ្លៃ ។ គន់មើលព្រះកេតុមិនផ្អែកក្តីសន្ធិះ ឱ
ប្រាង្គណ៍នេះមើលទៅផុតនិស្ស័យ យើងឥឡូវគិតទៅអាចិន្ត្រៃ
មិនគួរទៅជាព្រៃសូណ្យអសារ ។ យ៉ាងពីដើមមនុស្សច្រើន
បំរើណាចេះ បានជាធ្វើប្រាង្គណ៍នេះគួរអស្ចារ្យ ស្នាដៃធ្វើ
មើលស្មើព្រះពិសកាមិ តម្បិតជាស្នូលដែកសែកគ្នាជាប់ ។
បោះក្នុងប្អិតដ្ឋិតរលាយសាប់ ដល់យូរមកដែករេបដោយច្រេះ
ចាប់ នៅតែព្រង់អ្នកព្រៃប្រាជ្ញអាប់ ជាស្នាមម្រាមដៃចារ់
មនុស្សបូរាណ ។ ខ្លះសង្ស័យថាដៃព្រះឥន្ទ្រប្រើ ឲ្យវិស្សកម្មធ្វើ

ថ្វាយក្ស័ត្រក្សាន្ត ខ្ញុំគន់ៗ មើលសព្វមន្ទីរស្ថាន មិនសមដៃ មយវានលោកធ្វើឡើយ ។ ព្រះឥន្ទ្រអ្វីមកធ្វើមិនឲ្យស្រេប មើលទៅក្បាប់ខ្ទះគ្នាណាលោកអើយ ខ្លះអាក្រក់ខ្លះល្អមិនស្មើ ឡើយ បើព្រះឥន្ទ្រធ្វើហើយគង់ស្មើគ្នា ។ មួយវិញទៀតវិ-ស័យទេព្វនិមិត្រ ធ្វើដោយរិទ្ធិគិតថ្វាយស្តេចអង្គណា តែស្តេច នោះលុះអស់ព្រះជន្មា ទិនិមិត្រទៅជាផែនដីវិញ ។ នេះប្រា-សាទនគរនៅជាគឺ នឹងថារិទ្ធិនោះឬយ៉ាងនេះមិញ បើរិទ្ធិមែន ម្លែះសមរលីងធិញ ទីនេះមិញក៏ពេញទៅដោយព្រៃ ។ សង្ស័យ ប្វីនឹងដុំថ្មធំៗ គេលើកយកទៅផ្គុំបានទាំងផ្ទៃ គឺគេប្រើដោយ យន្តការវៃ នឹងបានប្រើដោយដៃនោះក៏ទេ ។ វិស័យជាងគេ បេះគ្នាគេប្រើន ស្តេចចំរើណដោយបុណ្យពីបុព្វេ នឹងធ្វើអ្វីក៏ ត្រេបចំណោះគេ កុំទៅគ្នេថាអង្គព្រះឥន្ទ្រសាង ។ មានអ្នក ខ្លះបួលចិត្តថាដីពិត គឺគេដុតយ៉ាងឥដ្ឋជាថ្មប្រាង្គណ៍ ព្រោះ ឃើញទីក្រសិន្ធុដ៏នៅខាង ទំនងយ៉ាងយកដីក្រសិន្ធុនោះ ។ ឱហ្ន៎ជាតិអ្នកខ្លៅដៅមិនចំ ម្តេចមិនមើលបែបពុម្ពតូចធំប្នោះ

មែនបើដីគេធ្វើមានពុម្ពនោះ គង់ប៉ុនគ្នាអស់នោះមិនព្នោះឬ ។ នេះមិនមែនប៉ុនគ្នាជាបែបពុម្ព ខ្លះក៏ធំខ្លះក៏តូចនៅជាគី បូរាណអ្វីឆោតម្លេះមិនដែលឮ មកប្រើងធ្វើដុំធំឲ្យធ្ងន់ក្រៃ ។ បើយ៉ាងឬបាយក្រៀមនោះយល់មែន ព្រោះផ្ទៃផែនស្មើគ្នាទាំងអស់នៃឯថ្មផុកអ្នកស្រុកកុំសង្ស័យ គឺសីម៉ង់ថ្មព្រៃយកពីក្រៅ ។ បើមិនជឿអញ្ជើញទៅមើលដាន ភ្នំខាងលើសឹងមានបំណាំងនៅទាំងថ្មហ៊ុបថ្មដាប់គរតាមផ្លូវ មានគេទៅបានឃើញជាអក្សរ ។ ខ្ញុំគន់មើលគិន្សរគួរជញ្ជាំង លើសកម្លាំងនឹងតែងឲ្យពិស្តារ វិលត្រឡប់ទៅមើលជាន់កណ្ដាល ឃើញព្រះរោងជ្រះប្រាលក្រសាលលន់ ។ ជើងសសរឆ្លាក់រូបតិសីសិទ្ធ អង្គុយបត់ជើងបិទប្រសិទ្ធមន្ត ផ្ទៃសសរមានអក្សរប្រកាសបុណ្យ ឲ្យមហាជនមើលដឹងដំណឹងទី ។ មានសករាជក្នុងរាជស្ដេចជាន់ក្រោយទ្រង់អំណោយសាងព្រះសាងគម្ពីរ បានលែងមនុស្សជាខ្ញុំថ្វាយព្រះអុន តាំងសញ្ញាឈ្មោះទុកនៅមុខព្រះ ។ លើពេតានធ្មិមខាត់បាត់ក្បាច់ផ្កាយ ឈូកសារ៉ាយណ៉ាយលយលកល្បះ ៗ

គ្រឹះប្រដាប់ប្អូនប៉ែកបែកស្រទ្បះ បន្លោះជ្រុងមានស្រះជា៤ដាន។ ឯស្រះនោះមានដក់ទឹកភ្លៀងស្អាត មច្ឆជាតិអាស្រ័យនៅជាស្ថាន ឥតបកព្រាស្មៅព្រៃផុកផង់គ្មាន ផ្ទៃសណ្ឋាន ៤ ជ្រុងស្មើភាគគ្នា ។ លោកប្រដាប់ដោយឬកដល់បាទ រលីងស្អាតសឹងរូតហ្វូតពេជា មានកើយកៃរជណ្ដើរបុះគង្គា មើលហាក់ជាស្ថានជ្រៅអណ្ដូងជ្រោះ ។ ខ្ញុំយល់ត្រីសង្ស័យហ្វូងមច្ឆ មកពីណាទៅមានក្នុងស្រះនោះ ស្រះលើប្រាង្គណ៍ផុតជាតិផែនដីសោះ នឹងមានជ្រោះហូរជ្រាបក៏គ្មានមុខ ។ ត្រីពួកនេះឧប្បតិកកើតឯងឬ ឬមួយគឺគេយកមកលែងទុក ខ្ញុំពិគ្រោះពុំឃើញមានទំនុក សែនជាទុក្ខនឹងត្រីពេញអស្ចារ្យ ។ នឹងមានអ្វីជាចំណីអាស្រ័យបាន បកសារ៉ាយក៏គ្មានជាអាហារ មានតែស្លែជុះជាប់តាមឬជា មើលអាការស្រះនោះជារណ្ដៅ ។ មានរោងទាំង ៤ មុមជុំស្រះស្រង់ ខ្នងបង្កង់ជាប់គ្នាជា ៤ ផ្លូវ ទ្វារឧត្ដរមានជ្រុងក្នុងយាងជ្រៅ នរណាទៅគោះទ្រង់ឮស្នូរគង។ មានអាការអស្ចារ្យទីនោះម្លេះ បូរាណរិះបេះធ្វើមានទំនង ផ្ទៃ

រាបស្មើពុំមានអ៊ីវង គោះតែទ្រុងឲ្យគង់សួរលាន់ៗ ។ ពោង ខាងត្បូងដីកល់ព្រះបដិមា ពុទ្ធបាទសាស្តាហៅព្រះពាន់ អង្គ ខ្លះឈរខ្លះគង់សង្រួមខន្ធ មានអរហន្តគង់គាល់ទាំងឆ្វេងស្តាំ ។ អង្គព្រះខ្លះពិការបាក់ស្វ៉ង នៅតែដងអង្គកាយគង់ប្រចាំ ព្រះ-ខ្លះឈរកណ្តៀវរាស៊ីសាំ បែកព្រះកាយបាក់ព្រះកាំស្រិាព្រះករ ។ មុខសប្បុបមានរូបប័ក្រពង្ស ពីរព្រះអង្គគឺព្រះកេតុចៅនគរ គង់ប្រណាម្យបង្គមលើកព្រះករ ឱនស្មោះសរតគុណព្រះជិនស្រី ។ តែរូបព្រះអង្គមួយដែលទ្រង់គ្រឿង ពាក់ជដារុងរឿងរៀររង្សី ខ្ញុំពុំស្គាល់ព្រះនាមជាស្តេចត្តៀ គ្មានបារិកនឹងស្តីថាស្តេចណា ។ គន់ព្រះរូបចិត្តរួញកង្ហញក្រាប សិរោរាបបង្គមព្រះសាស្តា សូត្រសរសើរពុទ្ធគុណអនន្តា ស្រេចទើបលាឡើងទៅជាន់ ទី៤ ។ ឋានខាងលើលោកធ្វើជាផ្ទៃរាន ជួរជុំមានសសរ បេញដោយខ្នន សឹងក្រឡឹងជើងទៀនដ៏មាំមួន មើលសិង្គូន ប្រមាណជារយប្លាយ ។ ខាងឆ្វេងស្តាំមានកឹងទាំង ២ ជាប់ ប្រែកបក្សាប់ខ្នក់ហៀននឹងល្អសលាយ តួកឹងនោះឥឡូវបាក់ធ្លាក់

ធ្លាយ គួរតែស្តាយកឹងឬអក្តរជាន ។ មើលបរិវេណបង្កាត់ ព្រះប្រាង្គណ៍ធំ រោងទងជុំតាមជាន់គ្រប់ៗជាន មានញក ញោបរួតះពេជ្រតាមសណ្ឋាន លើសប្រម៉ាណនឹងវាស់កត់ទ-យម ។ គន់ទី៤ ប្រាង្គណ៍៤ បត្តរស កំពូលខ្ពស់ស្មើគ្នាទាំង ៤មុម ខ្ញុំក៏ឡើងជាន់៥ប្រាសាទធំ ខ្ពស់ត្រសុមមើលត្រែសែត អណ្តែតចិត្ត ។ ភាពជណ្តើ ឡើងទៅក៏ខ្ពស់ហោត កាំនោះ សោតតូចៗជាន់មិនស្និត ប្រកាន់ដៃពុំមាននឹងយោងយឹត ខំកខិតឡើងទៅត្រាតែដល់ ។ គន់ជណ្តើរឡើងទៅ៩ស្ពាន ក្នុង១ជានពីរៗជុំមណ្ឌល់ មានរូតថ្ពាក់ល្បាក់ញកលោកដំ-កល់ ជាពើងទល់ទាល់ដល់ប្រកាន់លើ ។ តួប្រាង្គណ៍ទាំង៥ យ៉ាងចេតិយ៍ រូត៩ជ្រុង៨ជាស្មើៗ ទៀនប្រដាប់ពេជ្ររូត ច្រើនអន្លើ ត្របកស្មើជ្រុងមុមទាំង៤ជាន ។ មានទ្វារបួល៤ ទិសតែគេទាស់ បិទជិតអស់មិនឲ្យបួលទៅបាន ស្ពាងជាអង្គ ព្រះឈរប្រតិស្ឋាន ប្រចាំជានគ្រប់ទិសទាំង៤ទ្វារ ។ ខាង ក្នុងប្រាង្គណ៍យ៉ាងដាក់ព្រះមាសប្រាក់ ដែលបែកបាក់ធ្លាក់បង់

អង្គពិការ ឬរបស់ឯណាជាខ្លឹមសារ ក្រែងពួកចោរពួកមារវា
យាយី ។ លោកមោឆសៀវកុម្ម៉ែចៅភ្នាក់ងារ ឲ្យដាប់ទ្វារខាង
ប្ដៀងរូបព្រះដឺវ៍ រំលើងអង្គព្រះទ្វារចេញចាកទី រើយកព្រះ ខ្ចបខ្ចី
ពីក្នុងប្រាង្គណ៍ ។ ខ្ញុំយល់អង្គព្រះទ្វារគេដាប់ប្តេប បាក់ស្ប៉ាង
រូបខ្ទេចមិនយល់វាង នឹកសង្វែកព្រះទ្វារគេរំលាង ផុតវ៉ាង
សាស្នាព្រះទ្វារហើយ ។ ព្រះទ្វារទាំង ៣ លោកគង់សុខ
ពុំមានទុក្ខដួបអង្គព្រះប្ដៀងឡើយ ឱព្រះប្ដៀងពីថ្ងៃនេះទៅ
ហើយ រំលត់ខន្តកាន់ត្រើយនិព្វានហោង ។ ខ្ញុំខំចូលទៅ
មើលកន្លែងគុក ដែលគេតាំងព្រះទុកពុំឲ្យហ្មង មើលមិន
ច្បាស់ព្រោះដះភ្លិនម្តង ៗ គឺប្រចៀវខ្មៀវកងវ៉ាឧប្វារ ។
ទើបលាថយចុះមកគ្រឹះធរណី មើលពួកខ្មែរគូលីគេធ្វើការ
ដញ្ជូនយកអាចម៍ដីគីឧប្វារ ចេញតាមទ្វារទិសបូព៌បង្ហូរគ្នា ។
គន់មណ្ឌលព្រះប្រាង្គណ៍យ៉ាងល្បោល ៗ ពេលក្របីចូល
ក្រោលអស់សុរិយា ខ្ញុំនាំគ្នាចុះមកកាន់ពសុធា ទៅរកទីនិទ្រា
នារាត្រី ។ លុះព្រឹកឡើងជាថ្ងៃមួយដណ្តាប់ តិត្ថីជួនគំរប់ថ្ងៃសៅរ៍

លោកចៅហ្វាយក៏ដល់មណ្ឌលថ្មី ចែងសេចក្តីថាថ្ងៃនេះហ្លួងដល់ ។ ខ្លួនលោកមកជាមុនដោយប្រញាប់ នឹងអាលមកចាត់ចាំប់ឯមណ្ឌល ស្តេចនឹងយាងមកតាមវិថីថ្នល់ កំណត់ម៉ោង ១១ ដល់ព្រះពន្លា ។ លុះនិយាយបានតិចលេចកៅរីជិះពាជីមកដល់ចែងកិច្ចា ជុំរាបលោកសក្តិ ៣ រាជអាជ្ញា ថាឲ្យរៀបព្រះពន្លាស្តេចដល់ឆាប់ ។ លោកស័ក្តិ ៣ ឮឈ្មោះស្នុះម្នីម្នា ហៅពួកក្រុមឃោធាជាប្រញាប់ ព្រមទាំងពួកខុនឆាងគ្រប់សម្រប ឲ្យរៀបខ្លួនឈរចាំព្រះចក្រី ។ ក្រុមទាហានក៏រៀបក្បួនសះលុត ឈរបារុធវន្ទយ៉ាតាមថ្នល់ថ្មី ពួកអ្នកស្រុកក៏ផ្អើលទាំងប្រុសស្រី មកចាំមើលចក្រីមីត្រៀបត្រា ។ ខ្លះក៏បីកូនតូចដឹកកូនធំ អាតូចយំអាធំយិតស្មើរជាប់ស្មា ខ្លះក៏បាត់ប្អូនឃើញបងរកគ្នាឆ្លា ខ្លះឃើញយាយបាត់តាហៅគ្នាសាន ។ ខ្ញុំគន់ៗ អ្នកព្រៃបង់តែសើច ត្រកូលទើបមើលខាតខុសសណ្ឋាន ទាំងស្លៀកពាក់មិនសមនឹងខ្លួនប្រាណ សែនវិខានទាស់ភ្នែកប្លែកកន្លង ។ មានយាយចាសខ្លះនោះ

រូបពល្អក់ ទៅពាក់ការទំពក់ដូចគេបង ពាក់អង្កាំបារស្ពាន់
ព័ន្ធកម្រង មើលម្ដង ៗ បុះគន្លងព្នងពិត ៗ ។ ឱអ្នកព្រៃ
តែងត្លួតតសម្ណម ពុំបេះរៀបបេះបំតាមបារិត គន់អ្នកព្រៃ
មិនអសក្ដីអាណិត ហេតុតែក្រពិត ៗ ទើបយ៉ាងនេះ ។
អនិច្ចាអ្នកក្រត្រដមក ខំប្របៀតជ្រៀតជ្រិកនឹងគេប្ចេះ ខ្ញុំ
សម្ដេចបានតិបលេបឃើញសែះ ក្រម្ការគេជិះជាមគ្គទេស ។
ឃើញព្រះទីនាំងរាជរថពីរបវរ ទឹមអស្សុត្តរបរព្វូលដល់និវេស
ទ្រង់យាងបុះលោកធំបារាំងសែស គំនាប់តាមប្រទេសវេណី
ក្រៅ ។ នាយទាហ៊ានក៏ស្រែកក្បួនសះលុត ចាប់អាវុធវិទ្ធី
យារ៉េញ្ឈរនៅ ពួកនាហ្មឺនឱនកាយបង្គំទៅ ទ្រង់រ៉ាប់ផ្ទរបដិ-
សណ្ឋារ ។ លោកស័ក្ដិ ៣ ទទួលទីរ៉ាប់រង ជាបាលជូទូល
ស្នងការនានា គំនាប់ស្រែបស្ដេចឡើងកាន់ព្រះពន្លា អស់ព្រះ
ពញាហៃឡើងដំណាក់ស្ពាន ។ ដល់ព្រះទែនស្ដេចទ្រង់គង់
កៅអី លោកស័ក្ដិ ៣ អនុក្កូលទូលរ៉ាយង៉ាន រឿងអ្នកទោស
ដែលចាប់ពីក្រៅស្ពាន កាលពីស្រុកមោះមានអាចោរខ្លាំង ។

លោកឲ្យចាប់ទាំងជាទាំងកាបមក ព្រោះប្រាថ្នាដកយកស្បៀង
កម្លាំង នៃអាចោរទុច្ចរិតគិតតតាំង កាត់កម្លាំងពួកចោរមិនឲ្យ
នៅ ។ បានជាកៀរគ្រួមកព្រះដំបង ដាក់ទោសតាមទំនង
ដែលហ្មងសៅ បាំស្រុករាបកាលណានឹងលែងទៅ ដល់ឥ-
ឡូវស្រុកក្សាន្តបានសុខ ។ គួរមេត្តាយ៉ាងណាស្រេចតែទ្រង់
ឬបង្អង់ឈប់រង់មើលក្បិណរា ព្រះបមបេសជ្រាបច្បោះទ្រង់មេត្តា
ឲ្យលើកកាត់ទោសាពួកអ្នកព្រៃ ។ សន្ធរាបានតិបតាមនុសន្ធ៍
ឲ្យនិមន្តព្រះសង្ឃបួលថ្វាយជ័យ ជយន្តោថ្វាយពរក្សត្រជាថ្លៃ
តាមនិស្ស័យវេណីពីបូរាណ ។ លោកសង្ឃបើងព្រះដំបង
១០ អង្គគត់ វិន័យធរដើមបទជាប្រធាន រៀបព្រះអង្គបួល
កាន់ព្រះរាំងស្ពាន ទទួលក្តីរាប់អានតបក្រា ។ ទើបថ្វាយ
ព្រះជយន្តោពរភវ័ត បំរើនរាជពិភ័តមង្គលា លុះចប់ស្រេច
ស្តេចត្រាស់សន្ធរា ឲ្យសង្ឃលាទៅស្រុកតាមសម័យ ។
ព្រោះក្រែងជាប់វិស្សាការសៅហ្មង តាមទំនងសត្តាហ ៧ ថ្ងៃ
លោកស័ក្តិ៍ពទទួលទូលកៃខៃ សូមអំណាចក្សត្រថ្លៃឃុំវិស្សា ។

ប័ក្រពង្សពុំទ្រង់ឲ្យអំណាប    ព្រះទ័យខ្លាចក្រែងខុសក្នុងសិក្ខា
តែសត្តាហព្រះដំបងហួសហើយណា    ហ្វង់ឥកឋាក្រែងលោក
ទើបដល់ប្នី ។ ពុំជ្រាបហេតុព្រះសង្ឃព្រះដំបង    មកនៅចាំ
ភ៉ប់រងព្រះបក្រី    តាំងពីខ្នែត ១ កើតបួលតិត្ថី    ១១ សៅរ៍ហួស
កំណាត់ ។ សត្តាហបានតែ ៧ ថ្ងៃ    នេះហួសផុតនិស្ស័យ
សិក្ខាបទ    ថ្ងៃហ្វងដល់ ១១ កើតប្រាកដ    បើកំណាត់សត្តាហ
ហួស ៤ ថ្ងៃ ។ ហេតុដូច្នោះលោកសង្ឃព្រះដំបង    ដាច់
វិស្សាហើយហោងកុំសង្ស័យ    ខ្ញុំព្រះអាណិតលោកពេកក្រៃ
ឱម្ចាស់ថ្លៃក្រៃកបិនឃើញជាខាន ។ មួយអាណិតតែលោកវត្ត
និវេស    ជាប្រទេសមង្គលបូរីស្ថាន    ត្រូវទោសខុសកាលស្រុក
កើតមោះមាន ពួកទាហានបាញ់ចោរវិកល្បុក ។ លោកភ័យ
លោករត់ទៅនៅណោងបួ    ដល់ស្រុករាបតាំគ្រួសិស្សវិលស្រុក
លោករាជការឋាលោកតាំកល្បុក    ឲ្យឃុំខ្លួនមកទុកព្រះដំបង ។
ឃាំងនៅវត្តពីភិតជាយូរខែ    ទម្រាំតែផុតទោសដែលមោះហ្មង
មិនដឹងជាថ្ងៃណានឹងរួចហោង តែវនមួហ្មងបង់វិលទៅវត្តវិញ ។

រកឱកាសពុំបានរំខានចិត្ត សែនអាណិតគិតទៅគួរតែម្ទេញ លុះឮការឋាក្លេងស្តេចយាងចេញ ចាកភ្នំពេញមកផ្ទិនគរវត្ត ។ បានឱកាសដោយបេះក្បួនវត្ត កាំជ្រួចភ្ជីគោកោសម្រែកសត្វ លោកវត្តល្បៀបមេការទីបាល័ង្គ លោកក៏ចាត់ឲ្យទៅជាមួយផង ។ ឲ្យលោកជួយការភ្ជីទ័ឆ្លងបុណ្យ ថ្វាយព្រះគុណជាគុណព្រះប្ញាស់ប្ញង បានឱកាសនឹងទូលសូមទោសហោងនឹងបានវិលទៅគ្រងនិវេសវិញ ។ លុះឮហ្លួងប្រោសលែងអ្នកទោសបង់ ទាំងបាសកលោកសង្ឃជូប្ញោះមិញ មួយលោកសង្ឃ ៣ អង្គនៅភ្នំពេញ ឲ្យវិលវិញមកនៅតាមដើមដាន ។ ហៅអធិការនិវេសក៏ស្បើយទុក្ខ មានទឹកមុខរីករាយសប្បាយបាន ថ្វាយព្រះពរលាអង្គបមក្សត្រក្សាន្ត វិលទៅស្ថានទីលំនៅនៃអាត្មា ។ បមរាជាសទ្ធានឹងព្រះសង្ឃ លុះសុរិយង្គរះរេជ្រៃឆាយា សង្ឃទាំងឡាយក៏ថ្វាយព្រះពរលា ព្រះរាជាទ្រង់សោយដោយសម័យ ។ ស្តេចទ្រង់សោយព្រះស្ងោយវេលាជ្រៃ ស្ងួរេចសោយសុរិយេជ្រៃសែងប៉ៃ ទ្រង់បន្ទំសំរាន្តព្រះហឫ-

ទ័យ ពួកខាងណៃទាញផ្តិតផាត់ថ្វាយទ្រង់ ។ សែនកំសាន្ត
ក្សាន្តភិរម្យបរមនាថ ព្រះពាយផាត់គន្ធជាតិពិដោរហ្វង់ មហោរី
ប្រគំបន្លែងអង្គ បក្រពង្សទ្រង់ផ្ទំភិរម្យខ្វ័ន ។ លុះទិនករបរបែរ
ជ្រេរស្មី ព្រះបក្រីតើនបាកទែនសុវណ្ណ តែងព្រះអង្គបេញគង់
បុងរោងប័ន្ទន៍ ពួកកំណាន់គាល់វ៉ាប់ស្តាប់ឱង្ការ ។ អស់ជុំគុំ
មន្ត្រីកុង្សីយធំ មកដល់ជុំបាត់ទីតាមមុខងារ ក្រុមបោលិះតាំង
នៅប្រចាំទ្វារ មើលត្រួតត្រាវក្សាសត្រូវទ្រង់ ។ ពួកក្រុមវាំង
លោកវាំងនាយបាងហ្វោង ភ្នាក់ងារខាងស្តីការស្នំខាងក្នុង
ក្រុមដំរួតនាយត្រួតព្រះដំរង្គ លោកព្រះស្តេចស្តីការក្នុងសង្ឃ
ការី ។ អគ្គរាជយមរាជក្រុមៈមឿង សត្រីរឿងអាជ្ញាការផែនដី
ក្រឡាហោមបក្រីទីកុង្សីយ៍ ភ្នាក់ងារស្តីតាមទីបតុស្តម្ភ ។ ឯ
ខុនណាងខាងក្រៅណាកដំណែង ភ្នាក់ងារតែងគ្រប់មុខទាំង
តូបធំ សឹងព្រមព្រៀងនៅរៀងរោងថែវធំ តាមក្រុម ៗ
ខ្ញុំពុំស្គាល់ទេលោកអើយ ។ គ្រាន់នឹងតែងឲ្យគ្រប់ឈ្មោះ
អស់លោក គិតប្រយោគទៅទៀតពុំបានឡើយ ពេលក៏

ជូនចុះយប់ព្រលប់ហើយ ខ្ញុំក៏នឿយវិលទៅទីនិទ្រា ។ ពេលយប់នោះការហ្លួងទើបដល់ថ្មី ក្រុមមន្ត្រីសំរាកតែរាល់គ្នា ពុំទាន់មានរាជការនឹងពណ៌នា ខ្ញុំនិទ្រាលក់ទៅតាមសម័យ ។ លុះព្រឹកឡើង ១២ ថ្ងៃអាទិត្យ បមបពិត្រព្រះកែវហ្វាសុឡាវ៉ែ្ល ស្ដេចរៀបគ្រឿងព្លីការបូជាស័យ សូមពរជ័យទេវតារក្សាស្ថាន ។ មួយបូជាព្រះពាន់ពុទ្ធរូប នៅព្រះសប្តូបចេតិយ៍ពីបុរាណ ទាំងអ្នកតាមហារាជរិទ្ធីហាន តាមលំអានបុរាណរាជវេណី ។ លុះដល់ថ្ងៃ ១៣ តិត្ថប្ដូន ពួកខុននាងរៀបខ្លួនគ្រប់នាទី ចាំទទួលលោកធំចៅធានី គូវ៉ែរណើរមកពីព្រៃនគរ ។ លុះលោកដល់ក៏ចូលទីប្រជុំ ពួកមន្ត្រីតូចធំគ្រប់និករ សឹងទទួលគំនាប់ដោយសាទរ បមនគរក៏ទ្រង់ត្រេកគំនាប់ ។ លោកស័ក្តិ ៣ ថែមថីបកភាសា បែងកិច្ចាទទួលក្រះសសព្ទ ប័ក្រពង្សក៏ទ្រង់គង់ប្រថាប់ តាមព្រះច្បាប់ស្ដេចទ្រង់គង់ត្ដាំដៃ ។ លុះសុរេបសន្ធនាវេលានោះ គូវ៉ែរណើរលាចុះឡើងរថវៃ ទៅផ្ទះខាងប្ស៊ូងព្រះវាំងជ័យ សំរាប់ទីអាស្រ័យបារាំង

នៅ ។ ខ្ញុំមើលស័ក្តិ៥ហាមិនដាក់ យើញតែពាក់គ្រឿងស័ក្តិ ប៉ាក់ប៉ានឆ្អៅ រូបលោកទាបភាពធាត់មាត់ស្រម៉ូវ មើល ៗ ទៅគួរខ្លាចពុំអាចជិត ។ គេចមកមើលអ្នកលេងល្បែងបៀ ប៉ោ ខ្លះក៏ចាញ់សោកះប៉ៅស្វិត ខ្លះបានឈ្នះក៏ត្រេកដម្រែក ចិត្ត ខ្លះរេគិតកែកុនដោយកល់កោង ។ ខ្លះឈ្នះប៉ោចាញ់បៀ សសៀរធូ ចាក់ ១ តៅខុស ១ ត្លក់ស្បើយស្បោង បែត្រ-ឡប់ប្តូរប្រាក់ចាក់អាប៉ោង ត្រូវបិនកោងអស់ប្រាក់ធ្លាក់បក្ក ។ ចាប់យីគីស៊ុ ១ សងដល់ ១០ បិនប្រសប់លខ្មែរកែបញ្ញា ទោះជាត្រូវយួរទៅគង់អប្បរ៉ា បានដៃរាដាក់បង់កុំសង្ស័យ ។ ខ្ញុំមើលគេរេគិតដល់ខ្លួនឯង មិនគួរលុះការល្បែងឲ្យចង្រៃ ទុកទិញបាយបំណីត្រីអាស្រ័យ យល់ជាមានកំរ៉ៃបានឆ្អែត ពោះ ។ ឯជាតិល្បែងលេងភ្នាល់មិនទាល់បែះ ឈ្នះឯណុះ ចាញ់ឯណោះមិនខានសោះ ការលោភលង់គង់លាញប្រទាញ ឈ្មោះ តែដល់គ្រោះគង់ក្រកម្រក្រៃ ។ ខ្ញុំមើលគេបានតិច គេចទៅផ្សា ទិញបំណីអាហារបាយអាស្រ័យ ស្ទួរបេកិច្ចសុ-

រិយេជ្រើមាត់ព្រៃ បាត់សែងប្ញៃខៃខៃរង្សីសែង ។ ហៅភ្នាក់-ងារនាំគ្នាតែងរោងរាំ ទាំងរោងទងផ្ទេងស្គាំសឹងខ្វាត់ខ្វែង អុបប្រទីបផ្កាលាភ្លើងភ្លឺខែង ជាជួរវែងដល់ចុងផ្ទះបារាំង ។ លើខ្លោងទ្វារអុបជាត្រាផែនដី មកុដខ័នរង្សីព្រះពានតាំង ស្វេត្រ-ឆ័ត្រផ្ទេងស្គាំប្រចាំបាំង ភ្លឺទូទាំងរាជវាំងត្រឆាឆាយ ។ មើលពន្លឹកគ្រឹកគ្រឹនអាណែកក្រៃ ស្វាងទាំងព្រៃជាលជាស់ឱភាសសាយ បណ្ដាពួកប្រុសស្រីផងទាំងឡាយ សឹងសប្បាយនាំគ្នាមើលត្រៀបត្រា ។ លុះដល់ពេលហុំមរោងភ្នាក់ងារហោ៊ភិរីរោណែណាកជើតឈឹងឆា ពួកអ្នកស្រុកក៏ចូលមើលត្រៀបត្រា ណែនទាំងមហារាជរោងកងសព្វសែ ។ សឹងប្រៀបជ្រៀតគ្នាជែកមិនបុះ នរណាលុះក៏ស្ទុះទៅមុខគេ នរណាខ្លាចមិនអាចប្រៀបទេ ត្រូវឈរមើលក្រោយគេបើញត្រង ។ នរណាខ្ពស់គេគ្រាន់មើលស្រួលរាប នរណាទាបតោងរកជើងម៉ាត បើស្រីណាកាន់ខ្លួនថាជួនល្អ តែបួលទៅក្នុងបគង់អប្រិយ៍ ។ ពួកអ្នកលេងវាតែងដើរត្រដុះ ថាប្ហេះប្ហោះឲ្យលុះការលោកិយ៍ ខ្ញុំយល់ៗ

អាណិតពួកសត្រី ប្រុសអប្រិយ៍យាយីជាទីហ្មង ។ ខ្លះមានញាតិបងប្អូនជូនព្យាបាល រក្សាការណ៍ពួកពាលពុំកន្លង ឯណាគ្មានពួបពង្សវង្សផៅផង ពាលវាលងឡុកលួនកូនដោយកាម ។ អនិច្ចានារីរូបស្រឯំ មិនគួរមកមើលវាំឲ្យពាលតាម ជាកូនបៅនរណាម្ដេចមិនហាម បណ្ដោយតាមចិត្តកូនឲ្យខូចឈ្មោះ ។ ខ្ញុំឃើញគេឱបារការគួរស្អប់ គេបត្រឡប់ចាកចេញពីទីនោះ ដើរមកក្រៅមើលភ្លើងគេអុចប្រុះ ខ្ញុំដើរឆ្ពោះទៅស្ដាប់ភ្លេងបារាំង ។ ឃើញទាហានខ្មែរយើងរូបក្មេងៗ ឈរដឹកកង់តាំងលេងនៅមុខវាំង មាននាយត្រួតបន្លឺសព្ទដូចស័ង្ខ ស្គរមួយតាំងក្រាំងៗតាមចង្វាក់ ។ ត្រែតូចៗដូចក្លុយខ្លះវៀនជុំ ត្រែធំៗរុំឆ្វាយដូចជាឆ្នាក់ កាន់សៀវភៅរាល់ដៃផ្ទុំមើលថ្នាក់ ខិតៗដាក់តាមចង្វាក់ព្រមៗគ្នា ។ សែនពិរោះសព្ទត្រែសេលាន់កងបប៉ប៉ុះម្ដងឡើងថ្មីបំភ្លៃឃ្លា មេឡើងហៃបកូនឯបប្រសប់គ្នា ស្ដាប់ហោកជាភ្លេងកម្ពួលាន់ឮសាយ ។ ពួកបារាំងរៀបតាំងលៀងសុរា សព្វក្រយាអាហារគ្រឿងពីឆាយ ហោយបំរើទាញ

ផ្លិតជាប់រំភាយ កំសាន្តកាយដោយភ្លេងលេងប្រគំ ។ លុះម៉ោង ១០ ជួនយប់រួចការលៀង ពួកបារាំងព្រមព្រៀងទាំងតូចធំ នាំគ្នាដើរមើលការទីប្រជុំ សែនភិរម្យពេកះហោយសប្បាយក្រៃ ។ ពួកអ្នកលេងដើរទិញបារីស្លា ខ្លះបួលស្រាក់ទិញស្រាអាស្រ័យ ពួកអ្នកលក់ឃើញមនុស្សទិញច្រើនក្រៃ ដំឡើងថ្លៃយកកំរៃលើសប្រក្រតី ។ លុះព្រឹកឡើងថ្ងៃជ្រើព្រះទិន-ករ បមភួធរបេញគង់ព្រះរោងថ្មី ព្រមវង្សានុវង្សក្រុមកុង្ស៊ុយទាំងមន្ត្រីតូចធំជុំត្រៀបត្រា ។ មានដំម្រាស់ត្រាស់ឲ្យបាត់បែងទី រាជពិធីបំរើណាព្រះជន្សា មន្តព្រះសង្ឃសូត្រមន្តតាមវេលា បំនួនគ្រប់ជន្មា ៧០ ប្លាយ ។ លោកមង្គលទេពាចារ្យធំបំផុត· បំណែកខាងធម្មយុត្តិសង្ឃទាំងឡាយ លោកមហាភិមនកបភិប្រាយ ជាពួកខាងមហានិកាយអធិបតី ។ ព្រមព្រះគ្រូរាជាគណៈក្រៅ សឹងផ្ដុំនៅនាបុងព្រះរោងថ្មី ថ្វាយពុទ្ធមន្តចំរើនរាជសួស្តី មង្គលកិច្ចរំលឹស្រីសៈវត្តិ៍ ។ បក្រពង្សទ្រង់តាំងលោកពុទ្ធវង្ស ប្រោសឲ្យគង់ក្នុងដែនគរវត្ត ខាង

អាហារបាសកបេះបរិយត្តិ គឺអាហារអុំមគាត់បេះសាស្ត្រា ។ ប្រោសប្រទានគ្រឿងយសអាហារអុំម ឡើងជាធំទីសទ្ធម្មមេធា ជាបាងហ្វាងខាងពួកត្រៃវិជ្ជា ប្រចាំនានគរវត្តប្រាកដហោង ។ លុះពេលយប់អុបកាំជ្រួចរន្ទា ភ្ញីគោហានូវគ្រឿងដទៃផង ពួកលខោនក៏រាំជូបសព្វផង អស់មនុស្សផងមកមើលជួបសព្វគ្រា ។ លុះដល់ថ្ងៃ១៥វេលាព្រឹក មានពិធីផឹកទឹកព្រះសច្ចាប្រជុំពួកមន្ត្រីសេវកា ព្រាហ្មណ៍ហោរាជាធំក្នុងពិធី ។ តាំងនៅនាព្រះភ័ក្ត្រនៃព្រះពាន់ ព្រះបមខ័ណ្ឌក៏ទ្រង់យាងបរលីនាំព្រះវង្សកុង្សីយ៍ក្រមយោធី ឡើងកាន់ទីប្រាង្គណ៍ធំប្រជុំការ ។ លោកស័ក្តិ ៥ ស័ក្តិ ៣ ព្រៃនគរ ក៏ស្មោះសរបរតាមព្រះភូវិតារដ្ឋ ទាំងនាហ្មឺនក្នុងក្រៅគ្រប់មុខងារ ទទួលការទានទឹកប្រនិធាន ។ លុះជុំព្រមព្រាហ្មណ៍ហោរសូត្រពិធី ប្រនិធានតាមទីពីបូរាណ កួរអារុធពុះជាទិព្វញាណ សូរេបទើបរាជទានក្រមនានា ។ ចៅហ្វាយខែត្រសៀមរាបព្រះដំបង ជានាយកងក្រមក្រៅព្រះ-រដ្ឋា លោកកុង្សីយអធិបតីក្នុងសីមា ទទួលទឹកព្រះសច្ចាការភិ-

រម្យ ។ លុះសូរេចពិធីទឹកសម្បថ បក្រព័តិក៍ទ្រង់គង់ប្រជុំ
គូវិរណោរីរេស៊ុជងត៍កំពង់ធំ គាល់ប្រជុំជំនំតាមកិច្ចា ។ ទ្រង់
ឲ្យហូតនាទីអាជ្ញាហ្លួង នាយក្រសួងស័ក្តិ ៣ រាជអាជ្ញា ទាំង
លោកធំកុម្មីសែរជាឥស្សរា ឲ្យផ្លាស់វិលភារាភ្នំពេញហោង ។
យកលោកធំរេស៊ីដង់កំពង់ស្វាយ ឡើងជានាយកុម្មីសែរព្រះ
ដំបង មួយរាជកាសុខទុក្ខអស់រាស្ត្រផង ហៅហ្វាយខែត្រព្រះ
ដំបងជាឥស្សរា ។ លុះប្រជុំរួបស្រេចស្តេចវត្តី អញ្ជើញលីលា
រូបព្រះសាស្តា ទ្រង់យាងបាទចេញតាមទ្វារបច្ចិមា ព្រមព្រះ
វង្សពង្សាហែចេញប្តូន ។ ពួកអ្នកបិតបាំចិតព្រះរូបទ្រង់ ឲ្យ
ជាប់ជុំទាំងវង្សព្រះប្រាង្គណ៍ស្ថាន ខ្ញុំឃើញគេពេញកោតគេបំ-
ណាន បិតយកបានព្រះឆាយកាយភូធរ ។ លុះយាងដល់
រានហាលមុខព្រះលាន ពួកទាហានបារុធសៈលុតឈរ ស្តេច
ឡើងគង់ព្រះសៈលៀងរាជបវរ ពួកអ្នកសែងហែបរបូលរាំងប្ញី ។
លុះដល់គ្រែរេចស្តេចបូលព្រះរោងធំ ថ្វាយបង្គំព្រះសង្ឃទាំង
បាស់ខ្ចី អង្គាសភត្តភេសជបាយបំណើ ក្រុមសង្ឃការីបាត់ការ

បង្ហាន់សង្ឃ ។ ព្រះសង្ឃសូត្រទទួលរាជភត្ត តាមកំណត់ ពេលនោះថ្ងៃទៀបត្រង់ ស្រេចកិច្ចសង្ឃហៅព្រះចក្រពង្ស ស្ដេចក៏ទ្រង់ចូលកាន់ព្រះពន្លា ។ លុះដល់ពេលសូរិយេជ្រេស្រទន់ ឲ្យនិមន្តព្រះសង្ឃសង្គាយនា ចំនួនអង្គ ១០០ ដោយគណនា លោកទេសនាត្រៃ ៣ តាមព្រេងព្រឹល ។ ទីឧបាលីវិន័យធរ វត្តតាមិម អានន្ទគឺអាចារ្យគិមវត្តពិភិត ទីកស្សបព្រះគ្រូវត្តបូរពិត ចៅគណៈសង្ឃស្ថិតស្រុកសៀមរាប ។ សង្គាយនាបឋម តាមវេណី ក្នុងគម្ពីរបិដកតាមសភាព លុះចប់ចុះពេលថ្ងៃស្រទន់ទាប សង្ឃបានលាភក៏វិលវត្តអាត្មា ។ ពេលយប់នោះ មានការលេងអាប៉េ ក្បួនយីកេរាំឡកបកភាសា ពួកអ្នកស្រុកក៏មកមើលត្រៀបត្រា សែនមហាសប្បាយសោះសាយក្រៃ ។ លុះដល់ថ្ងៃ ១ រោជរូបពិធី ឲ្យបាត់ហែព្រះគម្ពីរបិដកថ្លៃ ចូលដឹកល់តាំងទុកនៅហោត្រៃ សម្រាប់នៃកុលបុត្រអ្នកសិក្សា ។ ថ្ងៃ ២ រោជញ្ញាចក្រពង្ស ក្រសាលស្រះស្រង់ទិសបច្ចិមា ឯខ្ញុំបានក៏នាំភៀនយាត្រា ទៅមើលក្រុងភារានគរធំ ។ លុះដើរ

ដល់ទ្វារគុមភ្នំបាខែង ព្រៃត្រសុមបាំងសែងសែនភិរម្យ ជើងគិរីមានសឹង្ហទាំង ២ មុម ឈរបំអែបែបំទិសប្ញាំ ។ សឹង្ហបា-សានបុរាណលោកសំអាង មើលដូចយ៉ាងសឹង្ហសត្វរាជសីហា ជាត់ក្រអួនខ្លួនក្រអាញក្រាញដូចខ្លា បំអេងស្មាឈរអើតបំ-ទើតជើង ។ ខ្ញុំយល់សឹង្ហឈរនឹងពុំកម្រើក បង់តែលើកយកមកទុកស្រុកយើង តែធំហួសផុតការលើកមិនឡើង នឹងប-ប៉ើងលើកយកពុំរួចឡើយ ។ អនិច្ចាសឹង្ហអើយសឹង្ហបាសានខ្ញុំយកទៅពុំបានណាសឹង្ហអើយ ឯងនៅចុះឲ្យសុខកុំទុក្ខឡើយកម្មសឹង្ហហើយមកនៅក្នុងព្រៃស្ងាត់ ។ បើសឹង្ហឯងរស់ពិតជីវិតមាន គួរជានៅសមសាន្តសន្តានសត្វ ស្វែងអាហារលៀងជីព្វពុំស្ងួវខាត់ នេះមកបាត់វិញ្ញាណមានតែប្រាណ ។ នឹងដើរទៅទីណាក៏ពុំកើត នៅតែឈរបំអើតប្រចាំដាន ស្តាយអើយស្តាយរូបសឹង្ហលោកបុរាណ ហោលក្នុងស្ថានស្មសានអានាថា ។ ខ្ញុំសម្តេទរូបសឹង្ហប្រឹងឡើងភ្នំ ឬត្បូបធំជិតជុំជាន់រអា ខ្ពស់ត្រឈឹងខំប្រឹងឡើងប្រវា៉ លុះដល់នាកំពូលគិរី

ស្ពាន ។ លើបាខែងលោកតែងជាសប្ជូប មានរូតរូប៥ជាន់ ជាជានៗ ខាងបូព៌ាមានប្រាង្គណ៍ទាំង៤ស្ពាន វិចិត្រដោយបាសានឥដ្ឋសិលា ។ ខាងមុខប្រាង្គណ៍មានល៉ាយព្រះបាទព្រះភិលស្រឡះពុំមានគ្រិះលេខា ជាប់ទំលុះធ្លុះបុះក្នុងសិលា ខាងលើលោកតាំងជាវិហារបាំង ។ តែវិហារនោះឯងលោកតែងឬធ្វើដោយឈើដោយឬស្សីប្រកស្បូវភ្លាំង ទីបូរាណមានតែរណ្តៅតាំង ឬរឹងគាំងនៅបណ្តោលគោលសីលា ។ ពុទ្ធបាទខ្នាតជ្រៅជុំរៀបាទ ប្លាយហាត់ខ្នាតបណ្តោយ៤ហត្ថា ទទឹងសោតពីរហត្ថជាមាត្រា ក្នុងបាទាលាយលក្ខណ៍កងច័ក្រជុំ ។ លោកវិចិត្របិទមាសវិលាសលឿង មើលរុងរឿងគួរយើងឡើងបង្គំ សព្វថ្ងៃមានលោកយួនគេជាធំ នៅថែទាំពិភក្ត៏រក្សាស្ពាន ។ ខ្ញុំយល់ព្រះពុទ្ធបាទអាណាបបិត្រ គិតដល់អង្គអគ្គនិដ្ឋព្រះទ្រង់ញាណ កាលព្រះអង្គស្តេចនឹងបូលនិព្វាន ព្រះទ័យមានមេត្តាដល់នរៈជាតិ ។ សត្វឯក្រោយពុំបានឃល់សាស្តា បានទាន់តែសាស្នាបរមនាថ ទើបប្រតិស្ឋានព្រះពុទ្ធបាទ

នឹងឱភាទឲ្យប្រោសអស់សត្វផង ។ ឱព្រះគុណបានបុណ្យលន់វិសេស ទ្រង់កំចាត់កិលេសជាគ្រឿងហ្មង បាននិព្វាននៅមានព្រះទ័យបង ដឹកលំបាទតាងស្នងព្រះពុទ្ធអង្គ ។ ទុកឲ្យសត្វឯក្រោយបានបូជា ជាផ្លូវទៅសួគ៌ាឋានទេពទ្រង់ សាងកុសលទាល់បានកាត់ភាគបង់ មិងយូរលង់គង់បានស្ថានសុខា ។ វេលានេះខ្ញុំមកដោយការខាត់ ពុំមានអ្វីប្រតិបត្តិចាត់បូជា មានតែដៃទាំង ១០ ខ្ញុំវន្ទា ចិត្តភាចាបូជាក្នុងគ្រានេះ ។ ឱព្រះបាទនេះជាព្រះជាត់ឬ ឬមួយគឺគេសាកទុកទេអែះ ក្នុងជម្រាពុំមានតាំងភ្នំនេះ បើតាមរិះយ៉ាងសំណាកគេសាកថ្មី ។ បញ្ជបាទទាំង ៥ សឹងមានដាន ឈ្មោះគេមានគ្រប់ស្ថានទាំង ៥ ទី ភ្នំបាខែងពុំមានក្នុងព្រះគម្ពីរ ដាក់ជាទីកើតក្រោយដោយនិយម។ ខ្ញុំវន្ទាព្រះបាទស្រេចលាចុះ ដម្រង់ឆ្ពោះកាត់ទៅមើលនគរធំផ្លូវជ្លាថ្កុល់សឹងឈើម្ចបត្រសុម គេរំលំកាត់ត្រង់នគរ ។ លុះដើរដល់ខ្លោងទ្វារនគរធំ សុទ្ធសឹងដុំថ្មជិតប្រកិតគ្នា កំពូលខ្ពស់សិនសេសដោយគណនា ចំលាក់ជារូបទេពប្រណម្យដៃ ។

កំពូលលើឈើដុះទំលុះបាក់ ថ្មរូសជ្រុះធ្លាក់ខ្ចាយរាយដោយព្រៃ នៅតែរាងដូបយ៉ាងព្រះប្រាង្គណ៍ជ័យ ចូលអាស្រ័យបុះមនុស្សដាងរយនាក់ ។ ផ្ទៃកំពែងតែងដោយថ្មក្រៀមក្រាសបូកដីដាសពាសប៉ះឡើងថ្នាក់ៗ កម្រាស់ក្រាស់ប្រមាណ ៣ ព្យាមជាក់ ធំអាណាក់វែងអនេកលើសគណនា ។ ក្រៅនគរតែងគូក្រសិនសាយ មើលវែងឆ្ងាយឱបអមនគរា តែឥឡូវស្បាតដិតដោយព្រឹក្សា បិទគង្គាកើតជាត្របតាប់តាន់ ។ មើលខ្លោងទ្វារពណ៌នាពុំអស់ក្បួន ពេលក៏ជួនទៀបទោរព្រះសុរិយ័ន ខំកាត់ចូលបូរីដោយបន្ទាន់ ដល់ប្រាសាទបាយ័នរាជភិរម្យ ។ ប្រាង្គណ៍បាយ័នលោកសាងជាប្រាង្គណ៍មូលមានកំពូលប្រាង្គណ៍បេញជា ៤ មុម ក្នុងកំពូលមួយៗឆ្លាក់រូបព្រហ្ម បួនៗជុំគ្រប់ប្រាង្គណ៍ប្រូងប្រាងក្រៃ ។ ឯរោងទងជុំវិញជ្រុងកែងកាត់ ទ្វារលោកបាត់កាត់មួយទ្វារ ១ នៃ ក្នុងឡប់ខ្សែបែមុខទៅទិវៃ បតុរស្សស្មើផ្ទៃបីដាន់សាយ ។ ឱប្រាង្គណ៍នេះមើលទៅតំរបើមលន់ ខ្ញុំគន់ៗគិតទៅគួរតែស្តាយ

ប្រាង្គណ៍នេះតើជាក់អ្វីពីព្រេងនាយ តាមបរិយាយគឺជាក់ភាពយោនី ។ គឺកាលដើមកាន់សាសនាព្រាហ្មណ៍ ប្រព្រឹត្តតាមធម្មតាព្រះសូលី យកយោនីឧមាភោគវតី ជាសិរីសួស្តីតាំងបូជា។ គេយល់ថាមនុស្សយើងក្នុងធរណី កើតចេញពីយោនីនាងឧមា នាងជាម្តាយមានគុណទាំងលោកា ទើបនាំគ្នាសាងជាកំណើតហោង ។ បើមានការមង្គលបំរើឥស្សរៈ ព្រាហ្មណ៍យកទឹកស្រោចភាពបង្ហូរត្រង់ មកប្រសិទ្ធិ៍ស្រោចអស់មហាជនផង បំបាត់ក្តីសៅហ្មងពាកឥន្ទ្រិយ៍ ។ ភាសាព្រាហ្មណ៍គេកាន់ជម្រាសែ ទើបកែខែចម្លងរូបយោនី សាងប្រាង្គណ៍នេះតាំងជាមន្ទីរទីលោកសញ្ញឹឲ្យហៅថាបាយ័ន ។ ឯសព្ទ-បា-នោះថាមួតមួយ ៗ តាមជំរួយសព្ទ-បា-គឺមួយខណ្ឌ យ័នសព្ទនេះពុំមែនជាលេខយន្ត កុំប្រកាន់យន្តលេខតាមភាសិត ។ សព្ទយ័ននេះគឺជាភាសាព្រាហ្មណ៍ មានក្នុងក្បួនសព្ទនាមប្លែងសង្ស្ក្រឹត ខ្ញុំមើល ៗ បាយ័នក៏ត្រូវចិត្ត នឹកអាណិតដល់ក្សត្រពីបូរាណ ។ លោកមានបុណ្យកសាងប្រាង្គណ៍បាយ័ន ទុកក្នុងខណ្ឌនិរោស

នៃក្សត្រក្សាន្ត មានទេសកាលក៏ឡើងប្រតិស្ឋាន ស្រោបស្រប
ប្រាណដោយទឹកនាងឧមា ។ សែនរុងរឿងភ្លើងបុណ្យភ្លើង
កេរ្តិ៍ឈ្មោះ កិត្តិសព្ទឮសុះសព្វភាវា បរទេសរាជកោតខ្លាច
ឡើងវិត្ថា រាស្ត្រប្រជាសឹងក្សាន្តសំរានកាយ ។ ឥឡូវព្រះនិ
វេសទៅជាព្រៃ ទាំងប្រាង្គណ៍ជ័យក៏ដល់ក្តីអន្តរាយ ឃើញ
តែស្មៅដែរធ្វើបែបឡើបខាយ ស្តាយអើយស្តាយមិនគួរមកប្តេះ
ណា ។ ទីខាងជើងមានវត្តលោកសង្ឃនៅ ព្រះនាមហៅព្រះ
ដោកលោកលេខា ឱព្រះដោកៗមែនឬយ៉ាងណា ឮគេថា
យល់ជាអស្ចារ្យក្រៃ ។ ខ្ញុំទៅមើលពុំឃើញព្រះលោកដោក
គិតប្រយោគយល់ថាព្រះម្ចាស់ថ្លៃ រូបព្រះធំលន់លើសព្រះដទៃ
ឯងវិតែមើលងុបដួបដោកមក ។ វត្តមួយខាងបស្ចិមគ្មានលោក
សង្ឃ កុដិវិហាររលួបបង់គ្មានទីជ្រក វត្តនោះឯងគេហៅវត្ត
គោកធ្លក តនោះមកវត្តប្ដូងបោលដួបគ្នា ។ វត្តនោះហៅព្រះ
ឥន្ទទេពកោសី អង្គព្រះជីក៏ធំសមរូបា កុដិវិហារបាំងព្រះគ្មាន
ឡើយណា អនិច្ចាមើលទៅសង្វេគក្រៃ ។ ឱអង្គព្រះឥន្ទទេពកោ

សីអើយ មិនគួរឡើយមកនៅកណ្តាលព្រៃ អាប់រាសីដោយសែងហែងដោយថ្ងៃ ទីអាស្រ័យពុំមានក្សាន្តព្រះកាយ ។ បើព្រះអង្គទៅគង់ស្រុកខ្ញុំរ៉ា ខ្ញុំនឹងសាងសាលាវិហារថ្វាយ ទាំងគ្រឿងតុគ្រឿងតាំងឲ្យឆើតឆាយ ដូចជាព្រះទាំងឡាយស្រុកព្រះដំបង ។ គ្រាន់និមន្តធន់លើកទៅពុំបាន ព្រោះធំហួសប្រមាណធ្ងន់កន្លង បើអង្គតូចទៅរ៉ានឹងរ៉ាប់រង ដាក់ដឹកឆ្លងមកស្រុកទុកបូជា ។ ឱលោកណាសន្ធាសាងព្រះនេះ ម្តេចមិនរិះត្រិះមើលដោយបញ្ញា កាលស្រុកដីមិនផុតក្តីអនិច្ចា មកគិតថានិច្ចំតាំងទៀងទាត់ ។ កាលប្រទេសរុងរឿងធ្វើតាមចិត្ត ដល់ប្រទេសវិបរិតកើតវិបត្តិ ព្រះជីធំនឹងរំកិលក៏កើតខាត់ តោងចាំកាត់ចិត្តចោលទុកច្នេះណា ។ បើយ៉ាងព្រះតូច ៗ ល្មមយករួច តែដល់ស្រុកខាត់ខូចដូចម្តេចម្តា ចង់រំលៀកក៏បានដូចចិត្តា ចុះដិម្រាធំខូចតូចមិនខាត់ ។ ដូចរាស្ត្រទាសតាំងឡើងជានាហ្មឺន ប្រព្រឹត្តកីនហួសការរាជបញ្ញត្តិ នឹងដកចេញចាកទីក៏មិនខាត់ តែមហាក្សត្រវិបត្តិដកពុំបាន ។ តោងចាំនៅទៅតាមយថាកម្ម

ទុក្ខក៏ទ្រាំទោសក៏ទ្រាំទម្រាំក្សាន្ត ដូចព្រះអង្គឥន្ទទេពជាបែប
មាន ក្សាន្តពុំបានព្រោះប្រាណធំលើសគេ ។ អនិច្ចាសាស្នា
ព្រះជិនវង្ស ពុំស្ថិតស្ថេរបេរលង់ក្នុងនគរ សោបុណ្យបាបអ្វីពី
បុព្វ បានជាប្រែប្រួលព្រៃដូច្នេះ ។ ស្រុកនេះសូន្យតើសូន្យ
ពីរាជណា ពង្សាវតារជម្រាងណាអែះ នឹងបានមើលឲ្យដឹង
រាជនោះនេះ ខ្ញុំនឹងត្រេះឲ្យត្រូវតាមល្បាក្សត្រ ។ ខ្ញុំគន់មើល
វត្ត ៣ ស្រែបបរបេរ ទៅមើលរាជមន្ទីរបក្រវត្តិ នៅខាងជើង
ព្រះដោកលោកបែងបាត់ ខឿនបង្វាត់ខ្វាត់ខ្វែងវែងរវឹង ។
ប្រាង្គណ៍ប្រាសាទបែកបាក់ធ្លាក់ខ្ទេចខ្ទី នៅតែទីគ្រឹះក្រោមកាត់
ទទឹង មុខប្រសាទស្ពានរាបភាពជាបឹង ជើងជណ្ដើរដើរមាន
សឹង្ហឈរប្រឹងប្រែង ។ ឯផ្ទៃផ្ដែរធ្លាក់រូបរឿងក្បួនខេន ជិះ
គជេន្ទ្រហៃស្វជាជួរវែង ខាងជ្រុង ៗ រូបគ្រុឌឈរបំទែង ខ្លះ
សម្ដែងបាប់រាសុក្រិក្រាយ ។ មុខព្រះលានមានប្រាង្គណ៍ជា
កាត់ ៗ ហៅប្រសាទសួព្រាត់ខ្ពស់ត្រសាយ ខ្ញុំយល់ ៗ នឹក
កោតគេអំបាយ ប្រាង្គណ៍ខ្ពស់ឆ្ងាយបងព្រាត់ហានសួរបាន ។

ទីខាងក្រោយប្រាសាទទៅបាត្បូន មើលក្បាច់ក្បូនឡប់ឡែជា
ជានៗ ឱបាក្ឃួនខ្លួននាងក្នុងវាំងស្ថាន ព្រួលកំសានលេងខ្លួន
បន្លែងអង្គ ។ ទីខាងជើងខ្លោងទ្វារមានគ្រឹះគ្រែ ជាថ្នាក់ហៃ
សឹងរួតហ្វូតហៀនហង្ស លើមន្ទីរសាងរូបចក្រពង្ស ស្ដេចគំ
លង់គង់នៅប្រចាំទី ។ ខ្ញុំយល់រូបព្រះបាទសង្ខច័ក្រ គេសាក
ដាក់ជាឡាក់រាជធានី កើតសម្ដេចវេទនាសល់សែនទ្វី មិនគួរ
ទីមកកើតវិបត្តិប្លេះ ។ ឮជម្រាបរម្យរាពីបូរាណ ជាព្រះបម
ក្សត្រក្សាន្ដនគរនេះ ប្រហារនាគឈាមនាគផ្សប់ផ្សាយផែះ
ត្រូវព្រះកាយកើតប្រែះប្រែជាឃ្លង់ ។ មើលពុំជាវេទនាពន់ប្រ-
មាណ ឥសីសានមកប្រស់ច័ក្រពង្ស ស្ដេចពុំជឿតាមពាក្យ
ឥសីសង្ឃ ទើបព្រះអង្គបង់ការអាសារកាយ ។ ឥសីទឹងផ្ដា
សារាជនិវេស ចោប្រទេសក៏លុះក្ដីអន្ដរាយ បានជាទីស្រុក
នេះកើតខ្វាត់ខ្វាយ ដោយបរិយាយជៅៗពុំពិស្ដារ ។ ខ្ញុំត្រេះៗ
នឹកតេះស្ដេចគំលង់ ព្រះទ័យទ្រង់មានះអហង្ការ កើតហេតុអ្វី
នឹងនាគទើបប្រហារ ឲ្យខូចត្រកុកអាសារស្មាដៃខ្លួន ។ គួរឬ

ក្រុងនគរេសប្រទេសធំ ប៉ុមកំផែងជិតជុំដ៏មាំមួន សត្រូវណានឹង
អាចចូលមកក្លួន តែគិតទៅចុះក្បួនព្រះត្រៃលក្ខណ៍ ។ សព្វសង្ខារ
មិនថាទាំងស្រុកដី ទូបូរីសាយសព្វគ្រប់ដំណាក់ ទុកជាបេះ
យ៉ាងណាក៏គង់ធ្លាក់ អញ្ជើញអ្នកមើលស្ដាប់ចាប់អារម្មណ៍ ។
នគរធំបរមបូរាណរាជ មើលគួរខ្លាចសឹងព្រៃស្រោងស្រាងជុំ
មានអ្នកស្រុកតាំងនៅជាជុំ ៗ រកស៊ីតាមនិគមអ្នកជនបទ ។
រយៈផ្លូវទៅដល់នគរធំ ដោយនិយមរាស់ពីនគរវត្ត ប្រមាណ
បាន ៩០ សិនប្រាកដ ចូរកំណត់កត់ចុះលោករាល់គ្នា ។
ក្រែងបានទៅនឹងងាយដឹងទិសទី រាជធានីបូរាណទិសឧត្ដរា
តែតំឡូវបារាំងគេកាប់ឆ្កា ទំនងជាយូរទៅគង់សប្បាយ ។
ខ្ញុំដើរគន់ដើរកត់នគរធំ ពុំបានជុំនគរទេលោកាយ ពេលក៏
ជួនសូរិយេជ្រេព្រះឆាយ ក៏រៀបកាយវិលមកសៀមរាបវិញ ។
លោកចៅហ្វាយលោកធំលោកស័ក្ដិបី សូរេចការបក្រីក្រុងភ្នំ
ពេញ បង្គំលាវិលព្រះដំបងវិញ ខ្ញុំក៏អស់ក្ដីម្នេញការលោកីយ៍ ។
ដល់មកស្រុកសាន្ដសុខឥតទុក្ខា ដោយអំណាចបប្រាគ្របកេ

សី ទាំងគុណកែវរតន៍ត្រៃថ្លៃទាំងបី ជួយបំរើនរាសីឥតហ្មង សៅ ។ រឿងនិរាសប្រកាសតែប៉ុណ្ណោះ សូមទុកស្នេះប្រារព្ធ បញ្ឈប់នៅ គ្រាន់នឹងតែងតអង្គព្រះបមបៅ កាលស្តេចនៅ ពុំទាន់វិលភ្នំពេញ ។ ខ្ញុំលាហើយពុំដឹងក្រោយយ៉ាងណា រាជ កិច្ចាពុំទាន់ប្រកាសបេញ ហេតុដូច្នោះទុកឲ្យប្រាជ្ញភ្នំពេញ គេ តែងបេញតរឿងព្រះបក្រី ។ ខ្ញុំតិត្ថាបារ្យបែងតែងពុំបាន ព្រោះ គ្មានដានលំអានយោគសេចក្តី ហេតុនោះសូមមេត្តាប្រោសប្រ ណី ខ្ញុំបញ្ចប់សេចក្តីតែប៉ុណ្ណោះ ។

សូមទោសលោកមេធីកវីជាតិ កុំឧបវាទពាក្យកាព្យខ្ញុំតែង នេះ សូមជម្រូវឲ្យត្រូវតាមលោកបេះ បើមិនដែះកុំបើកលើក បួលបេញ ។ កុំប្រមាទពាក្យកាព្យហាតែងងាយ យារមុខតាម និយាយដាក់បំពេញ បើមិនបេះពាក្យស្រួយខ្យល "រ" មិញ ឲ្យដេកវិញជាជាងកុំតែងឡើយ ។ មួយបើអ្នកឯណាបង់បម្លង តាមទំនងនិរាសនេះលោកអើយ បួលវាំងខ្យល់-រ-ល-ជាត្រើយ

តែបាត់ហើយខូបដល់ខ្ញុំអ្នកតែង ។ មួយស្រៈ .ៃ, រំភ្លៃនឹងស្រៈ .ី,
វិសញ្ជនីខ្យល់ .ស, លោកសម្តែង   កុំឲ្យប្ចូលយារមុខទង្គុកឯង
ឲ្យនៅតាមកន្លែងទីដោយខ្លួន   ពាក្យសំយោគការន្តវិធីសព្ទ
ប្ចូលលំដាប់រ៉ាប់គ្នាទៅតាមជួន  យោគសេចក្តីតាំងមុខឲ្យមាំមួន
រកបុងជួនមេកាព្យសភាពអើយ ។ ៚